ត្រឹង ងា
សាស្ត្រាចារ្យបរិញ្ញាផ្នែកវប្បធម៌ និងអរិយធម៌អាស៊ី
សាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ

# ប្រវត្តិសាស្ត្រខ្មែរ

(ពីការកសាងរាជធានីចតុមុខដល់ចុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស)

ភាគ 2

ការផ្សាយរបស់អ្នកនិពន្ធ

រក្សាសិទ្ធិគ្រប់យ៉ាង

ភ្នំពេញ គ.ស.១៩៧៣ ព.ស.២៥១៧

# បុព្វកថា

ការចងក្រងប្រវត្តិសាស្ត្រខ្មែរនៅចុងសម័យអង្គរ និងសម័យតៗ មកទៀតរហូតដល់ពេលបារាំងមកតាំងអាណាព្យាបាលភាពលើប្រទេសយើងនៅគ.ស.១៨៦៣ ជាកិច្ចការមួយពិបាកយ៉ាងក្រៃលែង ។ ឧបសគ្គចម្បងគឺ បណ្តាលមកពីកង្វះឯកសារ ជាពិសេសកង្វះខាតផ្នែកគុណសម្បត្តិនេះឯង ។ ឯកសារដែលយើងមាន គឺច្រើនតែជារាជពង្សាវតារ ។ ដូចយើងបានជំរាបអ្នកអានម្តងរួចហើយ នៅក្នុងភាគទី១ត្រង់ចំពូកទី៥ ស្តីពីប្រភពនៃប្រវត្តិសាស្ត្រខ្មែរថា : "រាជពង្សាវតារទាំងនេះបានរៀបចំឡើងនៅស.វ.ទី១៩ ដោយពឹងផ្អែកទៅលើការទន្ទេញចាំមាត់ខ្លះ និងលើអត្ថបទបុរាណខ្លះដែលពីដើមតំកល់ទុកនៅក្រុងឧដុង្គ" ។ គួរគប្បីជ្រាបថាមានតែក្បួនរាជពង្សាវតារមួយគត់ដែលបានចងក្រងឡើងនៅស.វ.ទី១៨ ហើយដែលសព្វថ្ងៃត្រូវបានគេយកទៅថែរក្សាទុកនៅឯប្រទេសថៃឯណោះ ។

បើដូច្នេះ អ្នកនិពន្ធដែលរស់នៅជំនាន់ក្រោយដល់ទៅ៤ ឬ ៥ សតវត្សមិនអាចជៀសវាងនូវការភ័ន្តច្រឡំក្នុងការរៀបរាប់ព្រឹត្តិការណ៍ឡើយ ។ អាស្រ័យហេតុនេះហើយទើបមានភាពខុសប្លែកគ្នាក្នុងផ្នែកព្រឹត្តិការណ៍ផង និងក្នុងផ្នែកកាលកំណត់ផង ពីក្បួនមួយទៅក្បួនមួយទៀត ។ មានក្បួនខ្លះដូចជាក្បួនរបស់ឧកញ៉ានង និងក្បួនវត្តសិត្បូរ មានកាលកំណត់ថយទៅក្រោយខ្លាំងពេក ក្បួនរបស់លោកវាំងជួន ឬ ក្បួនឆ្នាំ១៩០៧ ហើយប្រហែលជាក្បួនដែលគេបានប្រើប្រាស់ក្នុងការចារឹកអក្សរតំកល់នៅចេតិយវត្តភ្នំសព្វថ្ងៃនេះ មានកាលកំណត់ជាធម្យម ឯក្បួនខ្លះដូចជាក្បួនវត្តកោកកាកមានកាលកំណត់នោះខិតមកមុខពេក ។ ម្យ៉ាងទៀត ក្បួនរាជពង្សាវតារទាំងនោះរមែងបានគេកត់ចម្លងទុកតៗគ្នាមកទៀតជាហេតុនាំអោយរឹងរឹតតែមានការខុសឆ្គងផ្សេងៗទៀតជាមិនខាន ។ ចំពោះឯកសាររាជពង្សាវតារនេះ លោក Etienne Aymonier បានសរសេរថា : " C'est un document farci de dates peu sûres . . . une indigeste compilation de manuscrits douteux et incomplets "(1) (នេះជាឯកសារដែលពោរពេញទៅដោយកាលកំណត់មិនជាក់លាក់. . . ជាកំរងសាំញ៉ាំនៃអត្ថបទសរសេរដែពោរពេញដោយការសង្ស័យ និង ការខ្វះចន្លោះ) ។

កង្វះខាតខាងគុណសម្បត្តិនៃឯកសាររាជពង្សាវតារ គឺពិតជាមានដូច្នេះហើយ តែទោះបីយ៉ាងហ្នឹងក៏ដោយ ក៏អ្នកសិក្សាស្រាវជ្រាវនៅតែជៀសវាងមិនយកឯកសារទាំងនោះទៅប្រើពុំបានឡើយ ។ ចំពោះយើងវិញ យើងក៏ត្រូវជួបប្រទះនឹងឧបសគ្គយ៉ាងធំ ដូចដែលអ្នកសិក្សាស្រាវជ្រាវមុនយើងបានជួបប្រទះរួចហើយ ។ ប៉ុន្តែក្នុងការចងក្រងសៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ " ភាគទី២នេះ យើងនឹងខិតខំ

---

(1)(2)(3)...ជាលេខយោងទៅឯកសារពិគ្រោះ ដែលមានចុះនៅក្នុងបញ្ជីនៅខាងចុងសៀវភៅនេះ ។

ធ្វើយ៉ាងណាអោយស្របស្រួលទៅនឹងវិធីវិទ្យាសាស្ត្រជាអតិបរិមា ។ ក្នុងផ្នែកព្រឹត្តិការណ៍ ទោះបីមានក្បួនរាជពង្សាវតារខ្លះនិយាយក្បោះក្បាយ និងពិស្តារជាងក្បួនឯទៀតក៏ដោយក៏យើងពុំយក តាមតែក្បួនមួយៗ ហើយលះបង់ចោលនូវក្បួនឯទៀតទេ : យើងនឹងជ្រើសរើសតែត្រង់ចំណុចណាដែលក្បួនទាំងនោះនិយាយស្របគ្នា ឬក៏លើកមកជំរាបទាំងអស់តែម្តងទុកអោយមិត្តអ្នកអានវិនិច្ឆ័យ ខ្លួនឯងតាមគួរទៅចុះ ។ ម្យ៉ាងទៀត ទាំងខាងផ្នែកព្រឹត្តិការណ៍ និងទាំងខាងផ្នែកកាលកំណត់ យើងនឹងខិតខំធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងឯកសារបទេសនៅជិតខាងយើង និងឯកសារផ្សេងៗទៀត ក្នុងករណីណាដែលយើងអាចធ្វើទៅកើត ។

សៀវភៅ “ប្រវត្តិសាស្ត្រខ្មែរ ” ភាគទី២នេះ ជាកិច្ចការបន្តពីសៀវភៅ “ប្រវត្តិសាស្ត្រខ្មែរ ” ភាគទី ១ ។ ដូច្នេះ គោលបំណងរបស់យើងក៏មិនប្លែកអ្វីពីគោលបំណង ដូចយើងបានបញ្ជាក់ម្តងរួចហើយនោះទេ ។ ពេលនេះ យើងគ្រាន់តែប្រសិទ្ធពរសូមអោយកិច្ចការរបស់យើងនេះ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការបំរើជាតិដែរ ហើយសូមមិត្តអ្នកអានមេត្តាខន្តីអភ័យទោសអោយយើងតទៅទៀតចំពោះអំពើឆ្គាំឆ្គងកង្វះខាតគ្រប់បែបយ៉ាងដែលនឹងកើតឡើងដោយអចេតនាក្នុងការចងក្រងសៀវភៅ ភាគទី២នេះ ។

នៅទីបញ្ចប់នេះ យើងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងដ៏ស្មោះស្ម័គ្រជាទីបំផុតរបស់យើងចំពោះវរជន មិត្តភក្តិ និងសហការីផ្ទាល់ ដែលបានជួយជ្រោមជ្រែងទោះខាងផ្លូវចិត្តក្តី ខាងផ្លូវកាយក្តីខាងផ្លូវសម្ភារៈក្តី ហើយសូមអោយឧបការីទាំងនោះបានទទួលនូវកុសលផលបុណ្យ ដែលហូរចេញពីកិច្ចការនេះគ្រប់ៗគ្នាផង ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ១៩៧៤

**អ្នកនិពន្ធ**

# ជំពូក ៩

# ប្រទេសខ្មែរនៅពាក់កណ្ដាលទី២នៃសតវត្សទី១៥
## វិបត្តិក្នុងរាជវង្សខ្មែរ

## ក. ការកសាងភ្នំដូនពេញ

រាជពង្សាវតារខ្លះបាននិទានពីប្រវត្តិសាស្ត្រនៃក្រុងភ្នំពេញដោយមានសេចក្ដីសំរួលដូចតទៅ ៖

ក្នុងកាលដែលកន្លងយូរទៅហើយ មានស្ត្រីមេម៉ាយម្នាក់ជាអ្នកមានទ្រព្យស្ដុកស្ដម្ភ ដែលអ្នកផងហៅថា **ដូនពេញ** ។ ផ្ទះគាត់តាំងនៅលើទួលខ្ពស់មួយនៅលើត្រើយខាងលិចនៃ **ទន្លេច្រាបឈាម** (ទន្លេចតុមុខសព្វថ្ងៃ)

នាសម័យថ្ងៃមួយ ក្នុងរដូវវស្សាមានទឹកជំនន់នៅប្រទេសលាវយ៉ាងធំបណ្ដាលអោយបាក់ច្រាំងរលំដើមគគីរជាច្រើន ហើយអណ្ដែតបណ្ដោយទឹកតាមទន្លេមេគង្គរហូតមកដល់ទន្លេច្រាបឈាម ។ ក្នុងចំណោមនោះ មានដើមគគីរធំមួយ បានអណ្ដែតមកទើរនៅត្រង់មាត់កំពង់របស់ដូនពេញ ។ គាត់ក៏បានបបួលញាតិមិត្តជិតខាងជិះទូកទៅចងដើមគគីរនោះ ហើយនាំយកមកលើគោក ។ កាលបើអ្នកទាំងនោះរើសំរាមនៅគល់គគីរ ស្រាប់តែឃើញព្រះពុទ្ធរូបបួនព្រះអង្គ និងរូបបដិមាថ្ម មានលក្ខណៈជាព្រាហ្មណ៍ នៅក្នុងប្រហោងឈើនោះ ។ ពួកអ្នកស្រុកបានដង្ហែ រូបបដិមាទាំងនោះ យកទៅតំកល់ទុកនៅផ្ទះដូនពេញ ហើយគាត់បានអោយគេជញ្ជូនដី ពូនដំបូកធំខាងត្បូងសានផ្ទះ និងអោយគេយកឈើគគីរនោះសង់ព្រះវិហារតូចមួយនៅលើកំពូលភ្នំនោះ ហើយបានយកព្រះពុទ្ធរូបទៅតំកល់នៅក្នុងព្រះវិហារនោះនៅក្នុងឆ្នាំជូត ឆស័ក ព.ស. ១៩១៦ គ.ស. ១៣៧២ ។ តមកទៀតដូនពេញបានអោយ

គេសង់ខ្ទមមួយខាងទិសឦសានព្រះវិហារ រួចយកបដិមាថ្មទៅតំកល់ទុកនៅទីនោះ ហើយបានសន្មតថា **អ្នកតាព្រះចៅ** តរៀងមក (សព្វថ្ងៃគេហៅថា **លោកតាព្រះចៅ**) ។ ពិធីបុណ្យសម្ពោធក៏ត្រូវបានប្រារព្ធធ្វើឡើង ដើម្បីសម្ពោធពុទ្ធសេនាសនៈយ៉ាងអធិកអធម ។ ដោយអាស្រ័យហេតុនេះ ភ្នំនោះក៏មានឈ្មោះហៅថា **ភ្នំដូនពេញ** ហើយដែលយូរៗ ទៅក្លាយនៅត្រឹមតែ **ភ្នំពេញ** ដូចយើងហៅសព្វថ្ងៃនេះ ។

គួរគប្បីបញ្ជាក់ថា ចំពោះរូបបដិមាដែលដូនពេញបានរកឃើញក្នុងរន្ធដើមគគីរនោះរាជពង្សាវតារ និងអត្ថបទចម្លងតៗ មកទៀត និយាយមិនស្របគ្នាសោះ ខ្លះថាមានព្រះពុទ្ធបដិមា ៤អង្គធ្វើពីលង្ហិន និងបដិមាថ្មកាន់ស័ង្ខនិងគទា (ព្រះនារាយណ៍?) (2) ខ្លះថាមានព្រះពុទ្ធរូបពីរព្រះអង្គមានព្រះភ័ក្ត្រឈមជា ៤ ទិស (3) ខ្លះទៀតថាមានព្រះពុទ្ធរូបសំរិទ្ធមួយព្រះអង្គមានព្រះភ័ក្ត្រ ៤ តាំងសមាធិ និងរូបសិលា ១ ដៃកាន់ស័ង្ខមានផ្នួងសក់ ដូចជាពួកព្រាហ្មណ៍ (4) ។ តែបើតាមរូបតំណាងដែលមានតំកល់ក្នុងព្រះវិហារវត្តភ្នំ (ភ្នំដូនពេញ) សព្វថ្ងៃគឺជាព្រះពុទ្ធរូបប្រក់នាគ ៤អង្គគង់លើបុស្បុកទល់ព្រះប្រឹស្ឋ(ខ្នង) នឹងគ្នា ។

## ខ. ការកសាងរាជធានីចតុមុខ

ក្នុងភាគ ១ យើងបានឃើញថា នៅគ.ស ១៤៣១ ព្រះបាទបរមរាជាចៅពញាយ៉ាត ទ្រង់បានលើករាជធានីទៅតាំងនៅទួលបាសានក្នុងខេត្ត ស្រីសឈរវិញ តែគង់នៅទីនោះបានតែ ១ឆ្នាំ (ក្បួនខ្លះថាដល់ ៩ឆ្នាំ) ដោយមានទឹកជំនន់ធំខុសធម្មតា ព្រះអង្គក៏បញ្ជាអោយលើករាជធានីពីទួលបាសានទៅតាំងនៅក្រុងភ្នំពេញវិញ នៅលើត្រើយខាងលិចនៃទន្លេច្រាបឈាម ។

ព្រះអង្គទ្រង់ត្រាស់បង្គាប់អោយ **សម្តេចចៅពញាតែ** និង **ឧកញ៉ាមោហា ធិបតីខៀវ** ព្រមដោយមន្ត្រីឯទៀតខ្លះផងអោយទៅពិនិត្យមើលទីដីដែលស្ថិតនៅជិតៗភ្នំដូនពេញ ។ លុះទៅធ្វើការពិនិត្យក្បួនតម្រាសព្វគ្រប់ហើយ មន្ត្រីទាំងនោះក៏ថ្វាយដំណឹងទៅព្រះរាជាវិញថា តំបន់ដែលស្ថិតនៅទិសអគ្នេយ៍នៃភ្នំដូនពេញ មានជ័យភូមិល្អល្មមស្ថាបនារាជធានីបាន ។ ព្រះអង្គក៏ទ្រង់ត្រាស់អោយអស់ចៅហ្វាយស្រុកកែនរាស្ត្រ មកជួយកសាងព្រះរាជនិវេសន៍ លើកដីធ្វើកំពែង សង់ប្រាសាទ និងតំណាក់តូចធំក្នុងរយៈពេលដ៏ខ្លីបំផុត ។ លុះកិច្ចការបានបំពេញចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងមកគង់នៅរាជវាំងភ្នំដូនពេញតាមផ្លូវទឹកដោយមាននាម៉ឺនសព្វមុខមន្ត្រីដង្ហែមកផង ។

លុះយាងមកដល់ហើយ ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ **ចៅពញាតេជោ** ចៅហ្វាយស្រុក ខេត្តសំរោងទង អោយកែនរាស្ត្រលើកដីទៅចាក់បំពេញតំបន់នៅជុំវិញវត្តភ្នំ និងក្នុងរាជវាំង ។ ដូច្នេះតំបន់នោះក៏បានរាបស្មើល្អ រហូតដល់មាត់ទន្លេ ដែលអ្នកផងនិយមហៅ **កំពង់រាជ** ចាប់តាំងពីពេលនោះ

មក ។ ឯទីដែលថៅពញាតេជោអោយរាស្ត្រជីកយកអាចម៍ដីនោះ ក៏ក្លាយទៅជាបឹងមួយធំជ្រៅទូលាយ ទើបបានគេអោយឈ្មោះហៅ **បឹងតេជោ** តរៀងមក គឺទីដីត្រង់ផ្សារថ្មីសព្វថ្ងៃ ។

តមកទៀតព្រះរាជាទ្រង់ត្រាស់បង្គាប់ **ឧកញ៉ាចឲ្ធាអនុជិតផ្លុង** ថៅហ្វាយស្រុកខេត្តបាទីអោយជីកព្រែកបង្ហូរទឹកទន្លេចូលទៅក្នុងបារាយមួយ នៅក្នុងរាជធានីសំរាប់យកទឹកប្រើប្រាស់ដល់ប្រជារាស្ត្រទាំងអស់គ្នា ព្រែកនោះគេហៅថា **ព្រែកឧកញ៉ាផ្លុង** ។ បើតាមស្រាវជ្រាវទៅឃើញថា ពីដើមព្រែកនេះស្ថិតនៅតាមបណ្តោយសួនច្បារនៅមុខស្ថានីយកណ្តាលនៃអយស្ម័យយាន គឺស្របនឹងវិថីឧកញ៉ាផ្លុងសព្វថ្ងៃនេះឯង ។

ដើម្បីជាកិច្ចការពារ ព្រះរាជាទ្រង់បញ្ជាអោយជីកគូ និងលើកដីជាកំពែង តាំងជាសើន ជាបន្ទាយព័ទ្ធជុំវិញរាជធានី ។ ដូច្នេះ នៅទិសខាងត្បូងគឺ **ព្រែកតាកែវ** ខាងលិច **ព្រែកអូគរ** ខាងជើង **ព្រែកពោធិ៍ពាយ** ឬ **ព្រែកចិនជំដែក** ព្រោះនៅកន្លែងនោះមានជនជាតិចិនរកស៊ីរបរដំដែក ។ ក្រៅពីមុខងារការពារក្រុង ព្រែកទាំងនោះនៅមានមុខងារសំខាន់ម្យ៉ាងទៀតគឺយកទឹកសំរាប់អោយរាស្ត្រធ្វើស្រែនៅទិសខាងលិច ។

ពួកនាម៉ឺនសព្វមុខមន្ត្រី និងពួកប្រជារាស្ត្របានសង់គេហដ្ឋានរៀងៗខ្លួនក្នុងបរិវេណនៃរាជធានី ។ លុះសំរេចការកសាងហើយ ព្រះរាជាទ្រង់តាំងប្រទាននាមព្រះនគរថា **ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរ បវរ ឥន្ទបត្តបុរី រដ្ឋរាជ សីមា មហានគរ** ។ ចំណែកឯទន្លេប្រាបឈាម ក៏ត្រូវបានប្រសិទ្ធិនាមថ្មីថា ទន្លេចតុមុខ វិញដែរ ។

ក្រោយបន្តិចមក ព្រះរាជបុត្រច្បងព្រះនាម **នារាយណ៍រាជា** ទ្រង់បានតែងតាំងជាឧបរាជ ហើយយាងទៅគង់ក្នុងព្រះតំណាក់នៅ **ជ្រោយរលួស** ។ ឯព្រះរាជបុត្រទីពីរព្រះនាម **ស្រីរាជា** យាងទៅគង់នៅខាងលិច ត្រង់ដីទួលមួយកន្លែងដែលតមកគេហៅថា **ទួលព្រះស្រី** (ម្តុំវត្តព្រះពុទ្ធមានបុណ្យសព្វថ្ងៃ) ។ នៅគ្រានោះ ព្រះវិហារកសាងឡើងដោយដូនពេញក៏បានទ្រុឌទ្រោមខ្លះទៅតាមកាលវេលា ។ ព្រះបាទបរមរាជាថៅពញាយ៉ាតទ្រង់បានកសាងវិហារនោះជាថ្មីឡើងវិញ ដោយពង្រីក និងពូនភ្នំនោះអោយកាន់តែខ្ពស់ជាងដើម ហើយទ្រង់ចាត់អោយក្រាលថ្មនៅកំពូលខាងលើ និងកសាងចេតិយមួយយ៉ាងធំពីខាងក្រោយព្រះវិហារ ។ រួចព្រះអង្គទ្រង់បញ្ជាអោយទៅយកព្រះពុទ្ធបដិមាលង្ហិនដែលសេសសល់នៅនគរវត្ត ព្រមទាំងរូបសិង្ហតោ មកតំកល់ និងតាំងនៅលើភ្នំនោះ ។ ពិធីត្រូវធ្វើអស់រយៈពេលបីថ្ងៃ គេយកព្រះពុទ្ធបដិមាដែលដូនពេញបានរកឃើញពីក្នុងដើមគគីរពីមុននោះទៅតំកល់ក្នុងជាន់ខាងលើនៃចេតិយធំ ឯព្រះពុទ្ធបដិមាដែលយកពីនគរវត្ត ត្រូវបានតំកល់នៅក្នុងជាន់ក្រោម ។ វត្តភ្នំដូនពេញត្រូវប្រសិទ្ធិនាមថ្មីថា **វត្តព្រះចេតិយបព៌ត** វិញ ។

ក្រៅពីនេះ ព្រះរាជាទ្រង់បានចាត់អោយកសាងវត្តអារាមនៅច្រើនកន្លែងក្នុងរាជធានី ៖ វត្តពីរនៅខាងកើតវត្តភ្នំគឺ **វត្តធម្មលង្កា** និង **វត្តកោះ** វត្តមួយនៅខាងត្បូងអូចិនដំដែកគឺ វត្តព្រះពុទ្ធឃោសា (សព្វថ្ងៃហៅ **វត្តព្រះពុទ្ធឃោសារាម** ឬ **វត្តចិនដំដែក** នៅជាប់នឹងវត្ត ពិភទ្ធរង្សីមានវិថីឧកញ៉ាអ៊ុំខ័ណ្ឌកណ្តាល ។ នៅខាងមុខព្រះវិហារវត្តនេះ សព្វថ្ងៃគេឃើញមានរូបទ្វារបាលពីរនាក់ជារូបចិនដែលគេអាចមើលស្គាល់យ៉ាងងាយ ដោយសារលក្ខណៈ មុខមាត់ សំលៀកបំពាក់ និងគ្រឿងអាវុធ) វត្តមួយនៅត្រង់មាត់ទន្លេក្បែរពាមព្រែកឧកញ៉ាផ្លុងគឺ **វត្តពាមផ្ទុង** វត្តមួយនៅត្រង់ចេតិយធំ **វត្តឧណ្ណាលោម** ហើយវត្តមួយទៀតហៅ **វត្តខ្ពបតាយ៉ង** ។ គួរគប្បីកត់សំគាល់ថាវត្តចុងក្រោយនេះ សព្វថ្ងៃស្ថិតនៅត្រង់ **វត្តបទុមវតី** ។ បើតាមអក្សរចារឹកតំកល់នៅទីនោះ ព្រះបាទបរមរាជាចៅពញាយ៉ាតបានសាងវត្តនេះនៅ គ.ស ១៤៤២ លើទីមួយមានទំហំ ២០២ម × ២៦០ម ។ វត្តនេះគេហៅថា **វត្តខ្ពបតាយ៉ង** ព្រោះនៅខាងត្បូងមាន ខ្ពបរបស់តាយ៉ង ។ ព្រះវិហារវត្តនេះត្រូវបានកសាងថ្មីពីរលើកទៀត ៖ លើកទី១ នៅគ.ស ១៨៦៥ ក្នុងរជ្ជកាលព្រះបាទសម្តេចនរោត្តម លើកទី២ នៅគ.ស១៩៣៧ ក្នុងរជ្ជកាលរបស់ព្រះស៊ីសុវត្ថិមុនីវង្ស ។ គួរគប្បីជ្រាបម្យ៉ាងទៀតថា វត្តឧណ្ណាលោមនៅរក្សាឈ្មោះដដែលតាំងពីពេលកសាងរហូតមកដល់សព្វថ្ងៃ ហើយឈ្មោះនេះត្រូវបានប្រសិទ្ធឡើងដោយយកតាមឈ្មោះចេតិយដែលគេបញ្ចុះព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើមនៃព្រះ **អស្សជិតត្ថេរ** (5) ។ នៅខាងមុខវត្តនេះ គឺនៅជិតមាត់ទន្លេ ព្រះរាជាទ្រង់អោយសាងឃ្លាំងមឿងមួយ (អ្នកតាចាំស្រុក) ឈ្មោះ **អ្នកតាព្រាង្គ** ។


ព្រែកពោងពាយ
វត្តព្រះពុទ្ធឃោសា
បឹងកក់
វត្តលង្កា
ភ្នំដូនពេញ
វត្តកោះ
ព្រះរាជវាំង
ព្រែកអូរគរ
ខ្លាងមឿង
វត្តឧណ្ណាលោម
បឹងតេជោ
ព្រែកតាកែវ
បឹងកេងកង
ក្រុងភ្នំពេញ (ស. វទី១៥)
មាត្រដ្ឋាន : 1/20000

# គ. វិបត្តិក្នុងរាជវង្សខ្មែរ

## ១. ព្រះបាទបរមរាជា ចៅពញាយ៉ាត (១៣៩៣-១៤៦៣)

ព្រះបាទបរមរាជាចៅពញាយ៉ាត បានសោយរាជ្យនៅរាជធានីចតុមុខ ដោយបានសុខសាន្តរហូតរៀងមក ។ ឯកសារខ្លះបាននិយាយថា ប្រទេស ចិន យួន ចាម ជ្វា បាននាំគ្រឿងបណ្ណាការមកក្រាបទូលថ្វាយពឹងបុណ្យបារមីជាច្រើន ។ ឯកសារខ្លះទៀត (6) បានបញ្ជាក់ថា ពួកយួនដែលកំពុងចាប់ផ្តើមមកតាំងនៅប្រទេសកម្ពុជា គឺសុទ្ធសឹងជាពួកអ្នកជំនួញ និងពួកជាង តែការផ្ទៀងផ្ទាត់ជាមួយសៀវភៅប្រវត្តិសាស្ត្រយួនពុំឃើញមានបញ្ជាក់ពីចំណុចនោះសោះ ។ ចំពោះទំនាក់ទំនងជាមួយប្រទេសចិនវិញលោក Etienne Aymonier (7) បានសរសេរដោយរំលឹកសំដីរបស់លោកMoura ថា : “នៅឆ្នាំ១៤២១ ស្តេចចៅពញាយ៉ាត ដែលពួកអ្នកកាលប្បវត្តិចិន និយមហៅ Chieu-binh-nha បានបញ្ជូនរាជទូតទៅគាល់ព្រះចៅក្រុងចិន ។ រាជទូតរូបនេះ បាននាំយកព្រះរាជសារដែលព្រះរាជាទ្រង់បានសរសេរដោយព្រះហស្តផ្ទាល់ ហើយតំកល់ក្នុងហិបមួយធ្វើពីមាស ដែលត្រូវថ្វាយជាដង្វាយដល់ព្រះចៅក្រុងចិន ព្រមជាមួយនឹងដំរី ភ្លុកដំរី ល័ក្តម្រេច ក្រមួន កុយរមាស គ្រឿងក្រអូប សត្វក្ងោក... ” ។ គណៈបេសកកម្មទូតបញ្ជូនទៅប្រទេសចិន ត្រូវផុតរលត់សឹងតែអស់រលីងចាប់ពីគ.ស ១៤៣៥ ប៉ុន្តែគេឃើញពួកអ្នកតាកាលប្បវត្តិចិនបានកត់ត្រាទុកពីគណៈបេសកកម្មទូតមួយនៅគ.ស ១៤៥២ មានសេចក្តីដូចតទៅ : “ តាមក្រមនៃស្ថាប័នរាជវង្សមិង ឆ្នាំទី៣ គិងថៃ (១៤៥២) នៃរជ្ជកាលព្រះបាទ Tai-tsoung គេបានថ្វាយទៅព្រះចៅប្រទេសចិនឡានូវកំណាត់សូត្រប៉ាក់២ផ្ទាំង សំពត់ផ្កា៦ផ្ទាំង ស្បៃធ្វើពីសូត្រ ៤ផ្ទាំង ។ គេបានថ្វាយទៅព្រះអគ្គមហេសីសំពត់ផ្កា ៤ផ្ទាំង និងស្បៃ៣ផ្ទាំង លោកប្រធានគណៈបេសកកម្ម អ្នកបកប្រែភាសាទាំងអស់ និងពួកភ្នាក់ងារឯទៀតៗ បានទទួលនូវអាវផាយធំ សំពត់ផ្កា និងសំពត់សូត្រ ។ ពួកនេះបានទទួលការជប់លៀងភោជនាហារយ៉ាងអឹកធឹក ។ នៅពេលធ្វើដំណើរត្រឡប់មកស្រុកវិញ នាយក្រុមភស្តុភារនៃខេត្តក្វាងទុងបានទទួលបញ្ជាអោយធ្វើបដិសណ្ឋារកិច្ចចំពោះពួកនេះទៀត ។ ក្នុងរយៈពេលដប់ថ្ងៃដែលស្នាក់នៅ នៅប្រទេសចិន គេបានចែកអោយពួកនេះក្នុងមួយក្រុមៗមាន ១០នាក់ នូវចៀម២ ក្ងានញី២ មាន់ញី២ ស្រា២០ដប អង្ករ ម្សៅមី និងបន្លែសំរាប់ចំអិនធ្វើជាអាហារបរិភោគ” ។

គួរគប្បីជ្រាបថា ក្បួនរាជពង្សាវតារផ្សេងៗ បាននិយាយស្របគ្នាថា ព្រះបាទបរមរាជាចៅពញាយ៉ាត មានរាជបុត្របីអង្គ តែពុំសូវស្របគ្នាចំពោះនាមមហេសីរបស់ព្រះអង្គ :

១. **នារាយណ៍រាជា** រាជបុត្រ **អ្នកម្នាងទេពី** (ក្បួនខ្លះថា ជារាជបុត្ររបស់អ្នកម្នាងស្រីសៀមស្រងៀម ឬស៊ីសាងាម)

២. **ស្រីរាជា** រាជបុត្រ **អ្នកម្នាងចុងចកេសរ** (ក្បួនខ្លះថាជារាជបុត្រអ្នកម្នាង **ចន្ទ** ឬ **ចាន់**)

៣. **ធម្មរាជា** រាជបុត្រ **អ្នកម្នាងស្រីសៀមស្រទៀម** ឬ **ស៊ីសាខាម**

## ២. ព្រះបាទនារាយណ៍រាជា (១៤៦៣ - ១៤៦៩)

មកដល់គ. ស. ១៤៦៣ ព្រះបាទបរមរាជាចៅពញាយ៉ាត ទ្រង់បានបង្វែររាជសម្បត្តិទៅអោយបុត្រច្បង គឺនារាយណ៍រាជាដែលមាននាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះរាជឱង្ការព្រះនារាយណ៍រាជារាមាធិបតី ព្រះស្រីសុរិយោពណ៌ ធម្មិកមហារាជាធិរាជបរមបពិត្របណ្ឌិតជាតសូរ** គង់នៅរាជវាំងចតុមុខតរៀងមក ។

នៅគ. ស. ១៤៦៦ ព្រះវររាជបិតាបានសោយទិវង្គតទៅដោយជរារោគ ក្នុងជន្មាយុជាង ៧០ វស្សា ។ នៅគ. ស. ១៤៦៧ ព្រះអង្គទ្រង់បានសាងព្រះចេតិយនៅលើភ្នំដូនពេញ ដើម្បីធ្វើបុណ្យបញ្ចុះព្រះបរមអដ្ឋិព្រះបិតា។ សព្វថ្ងៃមានអក្សរចារឹកលើថ្មតាមបញ្ជារបស់ព្រះបាទសម្តេចព្រះស៊ីសុវត្ថិតំកល់នៅទីនោះតាំងពីគ. ស. ១៩១៧រៀងមក ។

## ៣. ព្រះបាទស្រីរាជា (១៤៦៩-១៤៨៥)

ព្រះបាទសម្តេចព្រះនារាយណ៍រាជាសោយរាជ្យបានតែ ៥-៦វស្សា (១៤៦៣-១៤៦៩) ក៏សោយទិវង្គតទៅដោយប្រឈួនជាទម្ងន់ ។ ឯកសារខ្លះបានបញ្ជាក់ថាព្រះអង្គមានរាជបុត្រជាមួយ **អ្នកម្នាងកែវ** ព្រះនាម **ស្រីសុរិយោទ័យ** ។ គេមិនដឹងច្បាស់ថា នៅពេលនោះព្រះរាជបុត្រមានជន្មាយុប៉ុន្មានវស្សាទេ តែបើតាមប៉ាន់ស្មានមើលទៅឃើញថាទំនងជានៅក្មេងពេកទើបព្រះរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីសូមយាងព្រះស្រីរាជាជាព្រះអនុជបន្ទាប់អោយឡើងសោយរាជ្យស្នងព្រះជេដ្ឋា ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះរាជឱង្ការព្រះស្រីរាជារាមាធិបតីធម្មិកវរឆ្គោមបរមមហាចក្រពត្រាធិរាជព្រះបរមនាថមហាបពិត្រ** ។

នៅគ. ស. ១៤៧១ ព្រះអង្គទ្រង់បានសាងព្រះចេតិយនៅខាងជើងភ្នំដូនពេញត្រង់ទិសឦសាន ដើម្បីធ្វើបុណ្យបញ្ចុះព្រះបរមអដ្ឋិព្រះនារាយណ៍រាជា ។ ចេតិយនេះបានស្ថិតនៅរហូតដល់សព្វថ្ងៃ ហើយមានអក្សរចារឹកតាមបង្គាប់របស់ព្រះបាទស៊ីសុវត្ថិតំកល់នៅទីនោះតាំងពីគ. ស. ១៩១៧រៀងមក ។

គឺចាប់តាំងពីរជ្ជកាលរបស់ព្រះបាទស្រីរាជានេះហើយ ដែលប្រទេសខ្មែរត្រូវពើបប្រទះនូវទុក្ខវេទនាយ៉ាងខ្លាំងបណ្តាលមកពីវិបត្តិក្នុងរាជវង្សខ្មែរ ។

ក្បួនរាជពង្សាវតារខ្លះបានសរសេរថានៅ គ.ស.១៤៧៥ ឆ្លៀតឱកាសដែលព្រះបិតុលា (ឪពុកមា) លើកទ័ពទៅវាយរំដោះយកអាណាខេត្តខាងលិចដែលត្រូវសៀមត្រួតត្រាជាយូរមកហើយនោះ

ដោយបានកៀរយកមនុស្សជាច្រើនពាន់នាក់នៅបស្ចិមបុរី នគរនាយកចូលមកប្រទេសខ្មែរ (8) ក្មួយរបស់ព្រះអង្គគឺស្រីសុរិយោទ័យមានចិត្តលោភចង់យករាជសម្បត្តិសោយ ក៏ថយពីចតុមុខទៅសង្កត់រាស្ត្រកទ័ពបានច្រើន ។ ពេលនោះព្រះធម្មរាជាជាឧបរាជ បានចាត់មន្ត្រីអោយទៅឈរខេត្តពីសំរោងទងដល់ទឹកខ្មៅ ហើយទ្រង់ចាត់អោយយកដំណឹងទៅថ្វាយព្រះស្រីរាជា ។ ព្រះអង្គក៏ប្រញាប់លើកទ័ពត្រឡប់មកវិញ ហើយចម្បាំងក៏ផ្ទុះឡើងរវាងមា និងក្មួយ ។ ក្បួនខ្លះនិយាយខ្លីជាងនេះ គឺមិនបានបញ្ជាក់ហេតុផលអ្វីអោយច្បាស់លាស់ទេ ។ ចំពោះប្រវត្តិវិទូបរទេសខ្លះមានលោក Dauphin Meunier ជាដើមទំនាស់នេះបណ្តាលមកពីព្រះសុរិយោទ័យយល់ថា ព្រះអង្គត្រូវតែមានសិទ្ធិសោយរាជ្យតពីព្រះបិតា គឺព្រះនារាយណ៍រាជា (9) ។

## ឃ. អន្តរាគមន៍របស់សៀម

ក្បួនរាជពង្សាវតារផ្សេងៗ សុទ្ធតែបាននិយាយពីអន្តរាគមន៍របស់សៀម ក្នុងជម្លោះរវាងស្តេចខ្មែរ ប៉ុន្តែរបៀបធ្វើអន្តរាគមន៍នោះឃើញថា មានបែបផែនខុសៗគ្នា ។

ក្បួនខ្លះបញ្ជាក់ថា គឺព្រះធម្មរាជាដែលត្រូវជាបុត្ររបស់អ្នកម្នាងសៀមស្រងៀមនេះឯងដែលទៅពឹងកម្លាំងសៀមដើម្បីដោះស្រាយបញ្ហាចម្បាំងក្នុងគ្រួសារផង និងដើម្បីបានសោយរាជ្យតែម្នាក់ឯងផង ។

### *ព្រះបាទធម្មរាជា (១៤៨៦-១៥០៤)*

នៅគ.ស. ១៤៨៥ ព្រះចៅមហាចក្រពត្រាធិរាជស្តេចសៀមសោយរាជ្យនៅក្រុងអយុធ្យាទ្រង់បានយល់ព្រមតាមសំណូមរបស់ស្តេចធម្មរាជា ហើយទ្រង់បានបញ្ជាអោយលើកទ័ពចូលមកក្នុងប្រទេសខ្មែរ ។ ដោយយល់ឃើញថា ប្រជានុរាស្ត្របាននឿយណាយនឹងសង្គ្រាមខ្លាំងពេកហើយ ព្រះបាទស្រីរាជាក៏ទ្រង់យល់ព្រមចូលមកផ្សះផ្សាបញ្ចប់សង្គ្រាម ។ ចំណែកឯខាងព្រះស្រីសុរិយោទ័យ ដោយពួកវរេហ៍ពលពុំព្រមច្បាំងតទៅទៀត ព្រះអង្គក៏ត្រូវបង្ខំព្រះហឫទ័យយាងចូលរួមក្នុងកិច្ចចរចារកសន្តិភាពដែរ ។ ជាកិច្ចដោះស្រាយ ព្រះចៅចក្រពត្រក៏បានសំរេចថាត្រូវតែចាប់ព្រះស្រីរាជា និងស្រីសុរិយោទ័យទៅគង់នៅឯស្រីអយុធ្យា ទើបប្រទេសខ្មែរបានសុខសន្តិភាពឡើងវិញ ។

ក្បួនខ្លះនិយាយថា ឆ្លៀតឱកាសដែលប្រទេសខ្មែរកំពុងតែមានចលាចលដោយសង្គ្រាមរវាងស្រីរាជា និងស្រីសុរិយោទ័យ សៀមបានលើកទ័ពចូលមកច្បាំងយកបានចន្ទបុរី មហានគរវត្ត នគរសេមា ហើយចាប់បានទាំងស្រីរាជា ទាំងស្រីសុរិយោទ័យ និងគ្រប់គ្រួរនាំទៅស្រីអយុធ្យា ហើយទុកនាយគង់អោយនៅថែរក្សាស្រុកភ្នំពេញ ។ គ្រានោះ ស្តេចធម្មរាជាដែលទៅឈរនៅនគរវត្ត បានថយទៅបាភ្នំកទ័ពមកច្បាំងយកបានភ្នំពេញ ហើយឡើងសោយរាជ្យដោយមានព្រះនាមថា **ព្រះបាទសម្តេចព្រះរាជឱង្ការព្រះធម្មរាជាមហាចក្រពត្រាធិរាជ** ។

ក្បួនខ្លះទៀតនិយាយថា គឺស្រីសុរិយោទ័យអង្គឯងតែម្តងដែលបានទៅពឹងអោយសៀមជួយ (9) ។ ពួកនេះបានលើកទ័ពចូលមកវាយយកបាននគររាជ អង្គរ ចន្ទបូរ ។ ចំណែកឯធម្មរាជា ដែលមានភារកិច្ចការពារក្រុងចតុមុខក៏បែរជាក្បត់ចូលដៃជាមួយសត្រូវប្រឆាំងនិងព្រះស្រីរាជា ជាស្តេចពេញច្បាប់ទៅវិញ ។ ស្រីសុរិយោទ័យលុះឃើញដូច្នោះក៏យាងទៅជួប និងស្តេចសៀម តែត្រូវចាប់នាំយកទៅប្រទេសសៀម ។

គួរគប្បីបញ្ជាក់ថា ព្រះស្រីរាជា និងស្រីសុរិយោទ័យសុទ្ធតែបានសុគតនៅប្រទេសសៀមទាំងពីរអង្គ(ក្បួនខ្លះថាសុគតនៅតាមផ្លូវ) ។ ព្រះស្រីរាជាមានបុត្រជាមួយ **អ្នកម្នាងកេសរ** នាម **ចៅពញាអុង** ។ ចំណែកឯព្រះធម្មរាជាត្រូវបានអភិសេកអោយឡើងសោយរាជ្យ នៅគ.ស.១៤៨៦ ហើយប្រទេសខ្មែរក៏បានសុខរៀងមករហូតដល់ពេលសោយទិវង្គតនាគ.ស.១៥០៤ ។ ព្រះអង្គមានបុត្រពីរអង្គ ៖

១. **ចៅពញាដាំខាត់រាជា** បុត្រអគ្គមហេសី **សម្តេចព្រះតគចតីស្រីទេពធីតា**

២. **ពញាចន្ទរាជា** បុត្រ **អ្នកម្នាងទេពច្ឆា**

ឯកសារខ្លះបានបញ្ជាក់ថា ព្រះអង្គជាព្រះរាជាដែលទ្រង់ប្រកបដោយទសពិធរាជធម៌ យកព្រះហឫទ័យទុកដាក់នឹងវាសនាប្រជារាស្ត្រ និងព្រះពុទ្ធសាសនាខ្លាំងណាស់ ។ ព្រះអង្គទ្រង់បានសាងព្រះចេតិយនៅខេត្តអាសន្ទុក ដើម្បីតំកល់ព្រះសារីរិកធាតុហើយមានព្រះហឫទ័យប្រាថ្នាចង់បានជាពុទ្ធភូមិទៀតផង ។

ក្នុងរយៈពេលជាងដប់ឆ្នាំគឺពី គ.ស. ១៤៧៥ ដល់ ១៤៨៥ ប្រទេសខ្មែរបានជួបនូវវិបត្តិមួយដ៏ធ្ងន់ដែលបណ្តាលមកពីទំនាស់ក្នុងរាជវង្សដែលដឹកនាំជាតិក្នុងពេលនោះ ។ ចំបាំងដែលជាវិធីដែលគេប្រើសំរាប់ដោះស្រាយជម្លោះនោះ បានធ្វើអោយអាណាប្រជានុរាស្ត្រមានទុក្ខវេទនាយ៉ាងសម្បើម បានធ្វើអោយសេដ្ឋកិច្ចចុះឱនថយ និងជាពិសេសធ្វើអោយប្រជាជាតិខ្មែរធ្លាក់ដុនដាបជាលំដាប់ ។ នេះជាលើកទី ១ ក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលគេឃើញមានស្តេចខ្មែរទៅអន្ទងពឹងពាក់បរទេសជិតខាងអោយចូលមកជួយដោះស្រាយបញ្ហារបស់ជាតិឯងផ្ទាល់ នេះគឺតំរាប់អាក្រក់មួយសំរាប់ព្រះរាជាសោយរាជ្យតៗមកហើយដែលបានរត់ទៅសុំជំនួយពីបរទេស ជាលេសអោយគេមានឱកាសលូកដៃចូលមកជ្រៀតជ្រែកក្នុងផ្ទៃរបស់ខ្មែរ ហើយទាញយកផលប្រយោជន៍អោយគេ ។ នេះក៏ជាលើកទី ១ ដែរដែលមានស្តេចខ្មែរទៅរស់នៅឯបរទេស **(ពញាអុង)** ក្នុងការទំនុកបំរុងរបស់គេ ។ ចំពោះរឿងនេះលោក Moura បានចាត់ទុកថាជាកលយុទ្ធមួយរបស់ស្តេចសៀម សំរាប់ទុកជាគូប្រជែងនឹងព្រះមហាក្សត្រខ្មែរអង្គណាដែលចង់រំដោះព្រះអង្គអោយរួចពីចំណុះរបស់សៀម (10) ។

# ជំពូក ១០

# ប្រទេសខ្មែរនៅសតវត្សទី ១៦
# វិបត្តិក្នុងរាជវង្សខ្មែរ និងការជ្រៀតជ្រែករបស់សៀម

## ក. ចម្បាំងគ្នាឯងក្នុងស្រុក

ចម្បាំងគ្នាឯងក្នុងស្រុកដែលបានកើតឡើងជាលើកដំបូងក្នុងសង្គមខ្មែរនៅពាក់កណ្ដាលទី ២ នៃ ស.វ.ទី ១៥ ត្រូវបាត់ស្ងាត់ទៅអស់មួយរយៈពេលហើយបានកំរើកឡើងវិញយ៉ាងខ្លាំងនៅខាងដើមនៃ ស.វ.ទី ១៦ ។

### ១. ព្រះបាទស្រីសុគន្ធបទ(១៥០៤-១៥១២) និងការជ្រែករាជ្យរបស់ស្ដេចកន

នៅពេលដែលព្រះបាទធម្មរាជា សោយទិវង្គតនៅគ.ស. ១៥០៤ បុត្រច្បងរបស់ព្រះអង្គគឺ **ចៅពញាដាំខាត់រាជា** បានឡើងសោយរាជ្យស្នងព្រះអង្គ ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទស្រីសុគន្ធបទ** គង់នៅរាជធានីចតុមុខ ។

ក្រោយបន្តិចមក ព្រះអង្គទ្រង់សព្វព្រះហឫទ័យលើករាជធានីទៅតាំងនៅ **ទួលបាសាន** វិញ ដោយព្រះអង្គទ្រង់យល់ថាទីនោះជាចំណុចយុទ្ធសាស្ត្រមួយ មានឧបសគ្គធម្មជាតិ (បឹងធំ ទន្លេព្រៃញ៉ិក) ស្រួលការពារខ្លួនជាងនៅក្រុងចតុមុខ ។ឯព្រះអនុជនាម **ពញាចន្ទរាជា** ត្រូវបានតែងតាំងជាមហាឧបរាជនៅ គ.ស.១៥០៨ ហើយនៅការពារក្រុងចតុមុខមើលខុសត្រូវលើអាណាខេត្តត្រើយខាងលិច ។

រាជពង្សាវតារបាននិយាយថា កាលដែលព្រះបាទ **ស្រីសុគន្ធបទ** យាងទៅគង់នៅរាជធានី **ទួលបាសាន** នោះ ព្រះអង្គបានលើកនាង **ស** (ឯកសារខ្លះថាឈ្មោះនាងពៅ) ជាស្នំឯកមាននាមថា **កេសរបុប្ផា** ទើបស្រុកនោះមានឈ្មោះថា **ស្រីសឈរ** ដែលតមកទៀតបានក្លាយជា **ស្រីសន្ធរ** រៀងរហូតមក ។ នាង **ស** នេះជាកូនរបស់មន្ត្រីម្នាក់ឈ្មោះ **ពិជ័យនាគ** និងនាង **បាន** ដែលជាពលព្រះស្រីរតនត្រ័យ ។ ប្អូនប្រុសរបស់នាង **ស** ឈ្មោះ **កៅ** ឬ **កន** ត្រូវបានតែងតាំងជាមហាតលិក ក្រោយមកទៀត បានឡើងឋានៈជា **ឃុនហ្លួងព្រះស្ដេច** មាននាទីមើលខុសត្រូវលើពលព្រះទាំងអស់ និងលើកិរិយាមារយាទនៃពលរដ្ឋទូទៅ ។

រាជពង្សាវតារបាននិយាយទៀតថា នៅគ.ស.១៥០៩ ព្រះបាទ **ស្រីសុគន្ធបទ** ទ្រង់សុបិនឃើញនាគរាជដេញខាំព្រះអង្គ ហើយខាំពាំស្វេតឆ័ត្រ ថែមទៀត ។ ព្រះអង្គទ្រង់បញ្ជាអោយហោរទាយ ថាមានកោលាហល អ្នកបង្កគឺ **ឃុនហ្លួងព្រះស្ដេចកន** ដែលកើតនៅឆ្នាំរោង (នាគ) ។ ស្របពេលជាមួយគ្នានោះមានពាក្យបណ្ដឹងមកថា មានកើតហេតុចម្លែកផ្សេងៗនៅក្នុងព្រះរាជាណាចក្រ ។ ដោយខ្លាចក្រែង **ស្ដេចកន** ក្បត់ដណ្ដើមរាជសម្បត្តិ សមដូចទំនាយរបស់ហោរានោះ ព្រះរាជាទ្រង់បានធ្វើការប្រជុំសម្ងាត់នៃពួកមន្ត្រីជំនិត ដើម្បីរិះរកមធ្យោបាយកំចាត់ **ស្ដេចកន** អោយបាន តែស្នំឯកលបលួចស្ដាប់ដឹងការណ៍ ហើយផ្ញើសំបុត្រទៅប្រាប់ប្អូនព្រះនាងយ៉ាងប្រញាប់ ។

តមក ព្រះរាជាទ្រង់បញ្ជាអោយពួកមន្ត្រីរៀបចំដង្ហែព្រះអង្គទៅក្រសាលបឹងបង់សំណាញ់កំសាន្តទៅតាមចំណូលព្រះហឫទ័យរបស់ព្រះអង្គដែលធ្លាប់តែធ្វើពីមុនរៀងមក ។ ស្ដេចកនក៏ត្រូវបានគេចាត់អោយទៅហែហមព្រះរាជាជាមួយនឹងមន្ត្រីឯទៀតៗដែរ ។ ដូចគេបានគ្រោងទុកជាមុនស្រេច ព្រះរាជាទ្រង់ធ្វើកលថា សំណាញ់ព្រះអង្គជាប់សំរាស់លើកពុំរួច ហើយទ្រង់បញ្ជាអោយ **ស្ដេចកន** មុជទឹកទៅដោះ ។ **ស្ដេចកន** ទទួលបញ្ជាហើយលោតទៅក្នុងទឹកធ្វើហាក់ដូចជាពុំដឹងខ្លួន ហើយមុជថយចេញពីកន្លែងនោះឆ្ងាយទៅ ។ ពេលនោះពួកបរិវារដែលជាជំនិតស្មានថា ស្ដេចកន បានធ្លាក់ចូលអន្ទាក់របស់ខ្លួនហើយ ក៏ប្រញាប់បង់សំណាញ់ព្រមគ្នាគ្របត្រង់កន្លែងដែល **ស្ដេចកន** លោតចុះទៅនោះ ដោយមានបំណងធ្វើអោយ **ស្ដេចកន** ជាប់សំណាញ់រើពុំរួច ស្លាប់នៅក្នុងទឹកនោះទៅ ។

លុះបានចាកផុតពីគ្រោះថ្នាក់ហើយ **ស្ដេចកន** បានភៀសខ្លួនទៅដល់ខេត្តបាភ្នំ ហើយប្រើឧបាយកលបោកបញ្ឆោតពួកចៅហ្វាយខេត្តថា ខ្លួនបានទទួលបញ្ជាពីព្រះរាជាអោយមកកែនទ័ពទៅកំចាត់មហាឧបរាជ **ចន្ទរាជា** ដែលមានចិត្តចង់ឡើងសោយរាជ្យនៅក្រុងចតុមុខ ។ ព្រះរាជា លុះបានជ្រាបដំណឹងថា **ស្ដេចកន** នៅរស់ហើយមានកទ័ពប្រឆាំងព្រះអង្គថែមទៀត ក៏ទ្រង់បញ្ជាអោយឪពុក និងបងស្រី **ស្ដេចកន** សរសេរសំបុត្រហៅត្រឡប់មកវិញ ។ **ស្ដេចកន** ប្រើឧបាយកលម្ដងទៀត ដោយប្រាប់ទៅពួកចៅហ្វាយខេត្តនិងអ្នកស្រុកថា ហ្លួងទ្រង់តឿនពីរឿងសង្គ្រាមទៅវិញ ។

ពាក្យឃោសនារបស់ **ស្តេចកន** បានលេចលឺទៅដល់មហាឧបរាជ **ចន្ទរាជា** ។ ព្រះអង្គនឹកស្មានថាមានហេតុមិនស្រួលក៏នាំព្រះរាជវង្សានុវង្សប្រញាប់ប្រញាល់ភៀសខ្លួនទៅសុំជ្រកកោននឹងស្តេចសៀមទៅ ។ កាលដែលយាងទៅខេត្តពោធិ៍សាត់ ព្រះ **ចន្ទរាជា** ទ្រង់បានទៅសំណាក់ផ្ទះមន្ត្រីម្នាក់ឈ្មោះ **ពេជ** ហើយទ្រង់បានទទួលការទំនុកបំរុងផ្សេងៗ ពីមន្ត្រីរូបនេះ ។

លុះដឹងថាព្រះ **ចន្ទរាជា** ព្រះអនុជ **ស្រីសុគន្ធបទ** បានយាងចេញផុតពីប្រទេសហើយ **ស្តេចកន** ក៏ចាប់ផ្តើមការវាយលុកចូលរាជធានីទួលបាសាន ។ ព្រះរាជាទ្រង់បានលើកទ័ពចេញតទល់ផ្ទាល់ព្រះអង្គតែត្រូវទទួលបរាជ័យ ហើយថយទៅកែនទ័ពថែមនៅក្រុងចតុមុខ ។ **ស្តេចកន** លើកទ័ពដេញតាមវាយបែកបន្ទាយភ្នំពេញទៀត ព្រះបាទ **ស្រីសុគន្ធបទ** ថយទៅគង់នៅលង្វែក ។ លុះបន្ទាយលង្វែកត្រូវវាយបែក ព្រះអង្គក៏យាងទៅគង់នៅស្រុកបរិបូណ៌ (**អច្រិន្ទបូរ**) រួចនៅទីបំផុត ទៅគង់នៅបន្ទាយស្ទឹងសែនក្នុងខេត្តអាសន្នុកនៅគ.ស.១៥១២ ។ ពេលនោះ **ឃុនហ្លួងព្រះស្តេចកន** ទៅតាំងទ័ពបោះបន្ទាយនៅទួលបាសាន ហើយប្រារព្ធធ្វើពិធីលើកខ្លួនឯងឡើងជាមហាឧបរាជ ។ រួចស្រេចហើយ ទ្រង់បានបញ្ជាអោយទ័ពលើកឆ្លងទៅបោះនៅកំពង់សៀមទៀត ។ **ស្តេចកន** បានក្លែងសំបុត្រផ្ញើទៅហ្លួងសុំចុះចូល តែសុំអោយម្តាយ និងបងប្អូនបានមកមុនសិន ។ ហ្លួងបញ្ជាអោយឆ្លើយវិញថា ត្រូវតែ **ស្តេចកន** ចូលខ្លួនមកមុន បើពុំដូច្នោះទេនឹងសម្លាប់ម្តាយ និងបងប្អូនទាំងអស់ ។ **ស្តេចកន** លើកទ័ពទៅជិតអាសន្នុក រកឧបាយយកម្តាយ និងញាតិសន្តានមកវិញ ។ ពេលនោះ មានមន្ត្រីម្នាក់ស្ម័គ្រចិត្តទទួលបំពេញកិច្ចការនេះថ្វាយ **ស្តេចកន** ឈ្មោះ **ឱកម៉ឺនសុរិន្ទតែវ** ។ កាលនោះគឺគេចោទថាមន្ត្រីរូបនេះក្បត់ ស្រាប់តែមានទាហាន២០០នាក់ជួយយកអាសា នាំទៅខាងបន្ទាយហ្លួងសុំចុះចូល ។ បន្ទាប់មក **ឃុនហ្លួងព្រះស្តេចកន** នាំទ័ពចូលវាយលុកបន្ទាយស្ទឹងសែនយ៉ាងខ្លាំង ។ ដោយទ្រង់ឈ្វេងយល់ថាមិនអាចទប់ទល់យូរអង្វែងតទៅទៀតបាន ព្រះរាជាគិតដកថយតាមជើងទឹកទៅកាន់ខេត្តពោធិ៍សាត់ តែពេលនោះ **ឱកម៉ឺនសុរិន្ទតែវ** និងបក្សពួកបះឡើងចូលចោមធ្វើគុតព្រះអង្គបានក្នុងបន្ទាយស្ទឹងសែននោះនៅ គ.ស. ១៥១២ ។ ព្រះរាជបុត្រព្រះអង្គនាម **ពញាឃសរាជា** (បុត្រជាមួយម្នាងកេសរបុប្ផា) និងបរិវារមួយក្រុមបានភៀសទៅជ្រកកោនក្នុងប្រទេសសៀមជាមួយព្រះ **ចន្ទរាជា** ។

**ឃុនហ្លួងព្រះស្តេចកន** ត្រឡប់មកទួលបាសានវិញ ប្រកាសអោយរកព្រះខាន់រាជ្យ ព្រះលំពែងជ័យ និងគ្រឿងព្រះបញ្ចក្សេត្រដើម្បីឡើងសោយរាជសម្បត្តិ ។ រាជពង្សាវតារខ្លះបានបញ្ជាក់ថា កាលដែលឡើងសោយរាជ្យនោះ **ស្តេចកន** មានព្រះជន្មាយុទើបតែបាន២៩វស្សា ហើយមាននាមសំរាប់រាជ្យថា **ស្រីជេដ្ឋាធិរាជរាមាធិបតី** ។ ព្រះអង្គទ្រង់បានបញ្ជាអោយមេទ័ព **កៅ** ដែលត្រូវជាឪពុកមាបង្កើតអោយលើកទៅបង្ក្រាបយកខេត្តទាំងឡាយណាដែលមិនទាន់ចុះចូលព្រះអង្គនៅឡើយ ។ លុះបានសុខសន្តិភាពបរិបូណ៌ឡើងវិញហើយ ព្រះអង្គទ្រង់លើកឪពុកមាអោយឡើងឋានៈជាស្តេចចៅហ្វ៊ាទឡ្ហៈ ឯពួកបរិវារឯទៀតក៏បានទទួលយសសក្តិទៅតាមគុណបំណាច់រៀងៗខ្លួនដែរ ។

នៅប្រមាណគ.ស. ១៥១៤ ព្រះបាទ **ស្រីជេដ្ឋា** ទ្រង់បានលើករាជធានីទៅតាំងនៅ **ចន្លក់ជូនតី** (នៅបានតែ ៥ ខែ) រួចលើកទៅតាំងនៅភូមិស្រឡប់នៅទល់ដែនខេត្តត្បូងឃ្មុំ និងខេត្តបាភ្នំ រាជធានីថ្មីនេះ ជាបន្ទាយមួយយ៉ាងមាំដែលព្រះអង្គប្រទាននាមថា ក្រុង **ស្រឡប់ពិជ័យព្រៃនគរ** ។

រាជពង្សាវតារខ្លះបានបញ្ជាក់ថា ព្រះបាទ**ស្រីជេដ្ឋា** ទ្រង់មានចំណូលហឫទ័យខាងបរបាញ់សត្វ ចាប់ត្រី ល្បែងស្រី ទតរបាំមហោស្រព តន្ត្រី ។ ក្នុងរជ្ជកាលរបស់ព្រះអង្គមានបោះប្រាក់ស្លឹង (សាច់ប្រាក់សុទ្ធ) មានរូបនាគសំរាប់ប្រើប្រាស់ក្នុងប្រទេស ហើយមានប្រវត្តិវិទូខ្លះបានសង្កត់សេចក្តីថា នៅសម័យនោះអាណាប្រជានុរាស្ត្របានសុខសម្បូណ៌សប្បាយថែមទៀតផង (11) ។

## ២. ចម្បាំងព្រះបាទស្រីជេដ្ឋា និងព្រះចន្ទរាជា (១៥១៦-១៥២៥)

និយាយពីព្រះ **ចន្ទរាជា** កាលដែលទៅសុំជ្រកកោនជាមួយព្រះចៅសៀមនោះ តែងតែយករបរទាក់ដំរីទៅបំរើព្រះអង្គ ។ លុះទ្រង់ជ្រាបថាព្រះរៀមត្រូវបក្សពួក **ឃុនឈ្លងព្រះស្តេចកន** ធ្វើគុតបានហើយ **ព្រះចន្ទរាជា** ទ្រង់រិះរកគ្រប់មធ្យោបាយដើម្បីបានវិលត្រឡប់ចូលមាតុប្រទេសវិញ ។ នៅគ.ស. ១៥១៥ ព្រះអង្គទាក់បានដំរីស យកទៅថ្វាយព្រះចៅសៀម ហើយសុំអនុញ្ញាត អោយធ្វើនិវត្តន៍ចូលស្រុកវិញ តែពុំបានសំរេចដូចប្រាថ្នាឡើយ ដោយហេតុនោះ ព្រះអង្គក៏ទ្រង់ប្រឌិតថា មានដំរីខ្ពស់ ១០ ហត្ថ (៥ម) នៅក្នុងព្រៃភូមិភាគខាងកើតនៃប្រទេសសៀម ។ លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះចៅសៀមក៏ទ្រង់ត្រាស់បញ្ជាអោយព្រះ**ចន្ទរាជា** ចេញទៅទាក់ដំរីនោះយកថ្វាយព្រះអង្គអោយបានក្នុងការបំពេញបេសកកម្មក្លែងបន្លំនេះ ព្រះ**ចន្ទរាជា** ទ្រង់បានទូលសុំពលចំនួន ៥០០០នាក់ ដំរីធ្លាក់ ១០០គ្រឿង សស្ត្រាវុធ ស្បៀងអាហារ និងដាវអាជ្ញាសឹក ។ ព្រះចៅសៀមក៏ទ្រង់បានយល់ព្រមតាមសំណូមពរគ្រប់ប្រការ ។

នៅគ.ស.១៥១៦ មុននឹងចេញបំពេញបេសកកម្មទាក់ដំរីនោះ ព្រះ**ចន្ទរាជា** ទ្រង់បានយាងទៅជួបជាសម្ងាត់ជាមួយនឹង **ពញាអុខ** ហើយបបួលព្រះអង្គអោយវិលត្រឡប់ចូលប្រទេសវិញ ។ កាលណោះ **ពញាអុខ** ជាបុត្រធម៌របស់ព្រះចៅសៀម ហើយត្រូវបានតែងតាំងអោយកាន់តំណែងជាចៅហ្វាយខេត្ត **សុវណ្ណខាត់លោក**ថែមទៀត ព្រះអង្គទ្រង់បានប្រកែកពុំព្រមវិលចូលមាតុប្រទេសទេ ដោយទ្រង់យល់ថា បានសុខសាន្ត និងបានយសសក្តិគ្រប់សព្វណាស់ទៅហើយ ។

ដោយមិនអាចទាក់ទាញ **ពញាអុខ** អោយធ្វើតាមព្រះអង្គទេ ព្រះ**ចន្ទរាជា** ទ្រង់បញ្ជាទ័ពអោយធ្វើដំណើរឆ្ពោះទៅទិសខាងកើត ធ្វើហាក់ដូចជាខំតាមដានដំរីស ហើយនៅទីបំផុតបានទៅដល់ព្រំដែនប្រទេសខ្មែរ ។ ព្រះ**ចន្ទរាជា** ទ្រង់ចាត់អោយគេនាំសារទៅថ្វាយព្រះចៅសៀមថា សុំទ័ពជាបន្ថែមទៀត ។ ប៉ុន្តែ **ពញាអុខ** បានទៅទូលថ្វាយពីល្បិចកិច្ចកលគ្រប់សព្វរបស់ព្រះ**ចន្ទរាជា** ព្រះចៅសៀមទ្រង់ខ្ញាល់

ណាស់ហើយទ្រង់បញ្ជាអោយលើកទ័ពទៅនាំព្រះចន្ទរាជាមកវិញ ។ ក្នុងកំឡុងពេលនោះ ព្រះ**ចន្ទរាជា** បានលើកទ័ពចូលទៅក្នុងដីខ្មែររួចជាស្រេច ។ លុះទៅដល់បាត់ដំបង ព្រះអង្គកែនបានពល ១០ ០០០ នាក់ ហើយលើកបង្ហួសឆ្ពោះទៅពោធិ៍សាត់ ។ លោកឧកញ៉ា **សួគ៌ាលោកកែវ** ចៅហ្វាយស្រុកខេត្តនេះ លុះបានដឹងហើយក៏ប្រញាប់ចាត់អោយនាំដំណឹងនេះទៅថ្វាយព្រះបាទ **ស្រីជេដ្ឋាធិរាជ** ។ ចំណែក **តាពេជ** បានប្រមូលបក្សពួក ហើយទៅវាយឆ្មក់លុកចូលបន្ទាយ ហើយសម្លាប់ចៅហ្វាយស្រុក **កែវ** បាន ។ គាត់ក៏ខិតខំបញ្ចុះបញ្ចូលអោយពលទាហានចូលខាងព្រះ **ចន្ទរាជា** ។ ព្រះអង្គសព្វព្រះហឫទ័យយ៉ាងខ្លាំងចំពោះថ្វីដៃរបស់ **តាពេជ** ហើយបានតាំងគាត់ជា **ចៅពញាសួគ៌ាលោក** ជាជំនួស **ឧកញ៉ាកែវ** ។ ម្យ៉ាងទៀត ព្រះ**ចន្ទរាជា** បានតែងតាំង**តាពេជ** ជាមេទ័ពធំនិងកូនទាំង ៤ នាក់របស់គាត់ជាមេទ័ពរង ហើយទ្រង់បញ្ជាអោយលើកទៅវាយយកខេត្តក្រគរ ខ្លុង ក្រង ។

លុះបានទទួលដំណឹងពីការវិលត្រឡប់មកវិញរបស់ព្រះ **ចន្ទរាជា** ភ្លាម ព្រះបាទ**ស្រីជេដ្ឋា** ទ្រង់បានបញ្ជាអោយចៅហ្វ៊ា **កៅ** លើកទ័ពទៅតទល់នៅត្រង់ក្រគរ ។ ដោយមានពលទាហានស្លាប់ច្រើនពេក **តាពេជ** បញ្ជាអោយទ័ពថយចូលទៅក្នុងបន្ទាយពោធិ៍សាត់សិន ។ ទ័ពខាងព្រះបាទ **ស្រីជេដ្ឋា** ក៏ដេញតាម ហើយទៅព័ទ្ធបន្ទាយជាប់អស់រយៈ ១២ ខែ តែវាយលុកចូលពុំបានសោះក៏ដកថយទៅតាំងទ័ពឆ្ងាយពីនោះ ដើម្បីរង់ចាំទ័ពជំនួយមកដល់ ។

គឺនៅក្នុងកាលៈទេសៈបែបនោះហើយដែល **តាពេជ** បានធ្វើពលិកម្មបូជាជីវិតដើម្បីទៅកែនទ័ពបិសាចមកជាទ័ពជំនួយ ។ បន្ទាប់ពីនោះ ការប្រយុទ្ធបង្ហូរឈាមបានកើតឡើងសាជាថ្មីទៀត រវាងទ័ពព្រះ **ចន្ទរាជា** និងទ័ពព្រះបាទ **ស្រីជេដ្ឋា** ។ នៅលើកនេះជ័យជំនះត្រូវបានទៅខាង ព្រះ**ចន្ទរាជា** ចំណែកឯចៅហ្វ៊ា **កៅ** បាក់ទ័ពថយទៅត្រើយខាងកើតវិញ ។

ក្នុងដំណើរជំរុលទៅមុខ ព្រះ**ចន្ទរាជា** បានលើកទ័ពវាយយកបានខេត្តជាច្រើនជាបន្តបន្ទាប់គ្នាគឺក្រគរ ខ្លុង ក្រង បរិបូណ៌ កំពង់សៀម ជើងព្រៃ ស្ទឹងត្រង់ ។ គ្រានោះ មានពួកខាងព្រះបាទ **ស្រីជេដ្ឋា** ដែលទទួលបរាជ័យនោះមកសុំចុះចូលជាច្រើន ឯពួកដែលរត់ពួនកាលព្រះបាទ **ស្រីសុគន្ធបទ** ច្បាំងចាញ់ឥឡូវចេញមកថ្វាយខ្លួនទាំងអស់ ។ ពួកនោះបានសុំអោយព្រះ**ចន្ទរាជា** ឡើងសោយរាជ្យ ព្រះអង្គក៏ព្រមឡើងគ្រងរាជ្យសិន ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបរមរាជាចន្ទរាជា** នៅគ. ស. ១៥១៦ ។

នៅឆ្នាំបន្ទាប់ (គ. ស. ១៥១៧) ដោយត្រូវទទួលបរាជ័យអស់ច្រើនលើកច្រើនសាមកហើយ ព្រះបាទ **ស្រីជេដ្ឋា** ទ្រង់ស្នើទៅព្រះ **ចន្ទរាជា** អោយផ្អាកសង្គ្រាមដើម្បីអោយរាស្ត្រធ្វើស្រែសិន ។ សំណើនេះក៏បានទទួលសេចក្តីយល់ព្រមពីព្រះ **ចន្ទរាជា** ។

ដល់ពេលចេញវស្សា ព្រះបាទ **ស្រីជេដ្ឋា** បានផ្តើមការវាយលុកម្តងទៀតដោយមានប្រើកលល្បិចអោយទាហានសុំចុះចូលខាងព្រះ **ចន្ទរាជា** ផងក្នុងបំណងធ្វើគុតស្តេចអង្គនេះអោយបាន តែមិន

បានសំរេច ឯខាងព្រះ **ចន្ទរាជា** ក៏មានប្រើល្បិចដូចគ្នាហើយមិនបានសំរេចដូចគ្នាដែរ ។ ព្រះអង្គក៏ថយទៅគង់នៅខេត្តពោធិ៍សាត់ ។ នៅគ.ស.១៥២០ អគ្គមហេសីគឺ **សម្តេចតគចតី សិរីចក្រពត្តិ** បានប្រសូតបុត្រនាម **ព្រះរាមាធិបតី** ហើយឆ្នាំបន្ទាប់មក ស្នំឯក **ចនុមបុប្ផា** បានប្រសូតបុត្រនាមព្រះ **បរមេន្ទរាជា** ។

នៅគ.ស.១៥២៥ ព្រះ**ចន្ទរាជា** ក្រោយដែលទ្រង់បានចាត់អោយទៅទិញកាំភ្លើងធំតូចពីប្រទេសម៉ាឡាយូមក ទ្រង់បានផ្តើមការវាយលុកទៅលើទ័ពព្រះបាទ **ស្រីជេដ្ឋា** ដែលទ្រង់បានរៀបចំធ្វើចម្បាំងដូចគ្នានេះដែរ ។ ព្រះ **ចន្ទរាជា** បានលើកទ័ពចេញជាបីផ្លូវ ។ ព្រះអង្គទ្រង់នាំទ័ពទៅវាយបន្ទាយស្រីសឈរដោយផ្ទាល់ព្រះអង្គ ។ ព្រះបាទ **ស្រីជេដ្ឋា** និងចៅហ៊្វាកៅ ខំវាយទម្លុះរត់ចូលទៅក្នុងបន្ទាយ **ស្រឡប់ពិជ័យ** ។ ព្រះ**ចន្ទរាជា** បញ្ជាអោយលើកទ័ពទៅវាយបន្ទាយនោះទៀត ។ នៅទីបំផុត ក្រោយពីបានតស៊ូយ៉ាងប្តូរផ្តាច់អស់រយៈពេល៣ខែមក ព្រះបាទ**ស្រីជេដ្ឋា** ត្រូវគេកាត់ព្រះសិរបានយកទៅដោតនៅមុខបន្ទាយក្រុង **ស្រឡប់ពិជ័យ** ឯចៅហ៊្វា**កៅ** ក៏ត្រូវគេសម្លាប់បានក្នុងបន្ទាយនោះដែរ ។ ដូច្នេះ សង្គ្រាមគ្នាឯងដែលមានរយៈពេល ៩ឆ្នាំ(១៥១៦-១៥២៥) ត្រូវបានបញ្ចប់នៅពេលនោះទៅ ។



## ខ. ការកសាងក្រុងលង្វែក និងការប៉ុនប៉ងរំដោះអាណាខេត្តខាងលិច

### ១. ព្រះបាទ ចន្ទរាជា (១៥១៦- ១៥៦៦) និងទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប

ដោយ **ពញាយសរាជា** រាជបុត្រព្រះបាទ **ស្រីសុគន្ធបទ** សោយទិវង្គតទៅ ព្រះ **ចន្ទរាជា** ទ្រង់បានយល់ព្រមឡើងគ្រងរាជ្យតាំងពី គ.ស.១៥១៦ ម្លេះទៅតាមសំណូមពររបស់រាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីរបស់ព្រះអង្គ ។ ក្រោយពីបានទទួលមហាជោគជ័យលើព្រះបាទ **ស្រីជេដ្ឋា** ហើយក៏ព្រះអង្គនៅតែបន្តការគ្រងរាជ្យតទៅទៀត ឯពិធីរាជាភិសេកឡើងសោយរាជ្យនឹងត្រូវប្រារព្ធធ្វើនៅពេលក្រោយទៀត គឺនៅពេលដែលរកឃើញព្រះខាន់រាជ្យ លំពែងជ័យ និងគ្រឿងបញ្ចក្បេត្រ ។ ព្រះអង្គមានរាជធានីតាំងជាបណ្តោះអាសន្ននៅក្នុងខេត្តពោធិ៍សាត់ ។

#### ១.១. ការកសាងក្រុងលង្វែក

ក្រោយមកព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យលើករាជធានីមកតាំងនៅក្រុងលង្វែកវិញ ។ រាជធានីថ្មីនេះត្រូវបានកសាងឡើងអស់រយៈពេលប្រហែល ៣ឆ្នាំ គឺពីគ.ស. ១៥២៧ ដល់ ១៥២៩ ។ ឯហេតុដែលនាំអោយជ្រើសរើសយកលង្វែក ដើម្បីជាទីតាំងរាជធានីថ្មីនេះ គឺព្រះ**ចន្ទរាជា** ទ្រង់ឈ្វេងយល់ថាកន្លែងនោះជាចំណុចយុទ្ធសាស្ត្រមួយស្រួលការពារខ្លួន ព្រោះនៅជិតនោះមានទន្លេ មានបឹង និងមានព្រៃទៀតផង បន្ទាយនេះមានរាងបួនជ្រុងទ្រវែង ទទឹងមានប្រវែង ២គ.ម. ឯបណ្តោយមានប្រវែងជិត ៣គ.ម. មានកំពែងដី គូទឹក និងរបងឫស្សីកំរាស់ពីរសិន (១៦០ម) ព័ទ្ធជុំវិញ (សូមមើលផែនទី ដែលយើងបានគូរតាមពត៌មានផ្តល់ដោយលោក អ៊ុក អ៊ូ ដែលបានកាន់តំណែងមេឃុំ ឃុំលង្វែកអស់រយៈពេលជាង១០ឆ្នាំ និងតាមការដែលយើងបានទៅពិនិត្យដល់ទីកន្លែងកាលពីថ្ងៃទី៨ ខែមីនា ១៩៧០ នៅតំបន់ឧដុង្គ និងលង្វែក) ។ តាមពាក្យដំណាលតៗមក គេថាលង្វែកជាបន្ទាយមួយធំសម្បើមអស្ចារ្យណាស់ សូម្បីតែសេះដែលមានកម្លាំងខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏មិនអាចបោលអោយជុំបន្ទាយនេះបានឡើយ ។ ម្យ៉ាងទៀតតាមជំនឿរបស់ខ្មែរយើងថា នៅក្នុងបន្ទាយលង្វែកនេះមានគេតំកល់រូបបដិមា **ព្រះគោ** មួយអង្គ និង **ព្រះកែវ** មួយអង្គ ដែលជាបងប្អូនបង្កើតនឹងគ្នា ហើយដែលអ្នកស្រុកតែងតែគោរពបូជាទុកជាវត្ថុសក្តិសិទ្ធិ ។ ដោយហេតុនោះគេតែងយកក្បួនច្បាប់ផ្សេងៗទៅទុកក្នុងពោះ**ព្រះគោ**នោះ(១២) ។ ទោះបីជំនឿខាងលើនេះមានលក្ខណៈជារឿងព្រេងក៏ដោយ ក៏ចំណុចនេះបង្ហាញអោយយើងឃើញថាលង្វែកជាបន្ទាយមួយមាំមួនសំរាប់ការពារសត្រូវឈ្លានពានផង និងជាឃ្លាំងវប្បធម៌មួយរបស់ជាតិបន្ទាប់ពីរាជធានី **អង្គរ** មកផង ។

លុះការស្ថាបនាព្រះរាជវាំង និងដំណាក់ធំតូចបានចប់សព្វគ្រប់ហើយ ព្រះបាទ**ចន្ទរាជា** ទ្រង់យាងមកគង់នៅរាជធានីថ្មីនេះប្រមាណឆ្នាំ ១៥២៩ ។ ព្រះអង្គជាមហាក្សត្រមួយអង្គដែលមានជំនឿមុតមាំលើព្រះពុទ្ធសាសនា ។ ក្រៅពីវត្តអារាមជាច្រើនដែលព្រះអង្គទ្រង់បញ្ជាអោយសាងនៅពោធិ៍សាត់ និង **ចរិមុណ្ឌិ** និងអោយសាង និងជួសជុលនៅ **ឧដុង្គ** មានវត្តលើ **ភ្នំព្រះរាជទ្រព្យ** ជាដើម (ព្រះពុទ្ធរូបចូលនិព្វាន) ព្រះអង្គបានអោយសាង **វត្តត្របែកឡែងកែង** នៅក្នុងបន្ទាយលង្វែកទៀត ។ តាមដែលមើលឃើញសព្វថ្ងៃ ព្រះវិហារវត្តនេះស្ថិតនៅលើដីទួលមួយមានរាងជាជើងក្អែក ។ ក្នុងព្រះវិហារមានតំកល់ព្រះ **ពុទ្ធរូបត្របែកឡែងកែង** គឺព្រះពុទ្ធរូប ៤ អង្គគង់ឈរ ទល់ព្រះប្រឹស្ឋ (ខ្នង) នឹងគ្នា ហើយបែរព្រះភក្ត្រទៅទិសទាំង ៤ ។ ក្នុងសម័យនោះ ខ្មែរយើងបានចាត់ទុកថាព្រះពុទ្ធរូបត្រឡែងកែងនេះជាវត្ថុសក្ដិសិទ្ធិមួយដែរ ។




## ១.២. ទំនាក់ទំនងជាមួយសៀម

លុះដឹងថា **ព្រះចន្ទរាជា** បានកាន់កាប់អំណាចស៊ប់នៅប្រទេសខ្មែរហើយ ហើយដោយចាត់ទុកថា ប្រទេសនេះជាចំណុះប្រទេសសៀមតាំងពីរាជព្រះបាទ **ឆទ្ទរាជាទី** ១មកម្ល៉េះនោះ ព្រះចៅសៀមបាន

ចាត់ទូតមកបញ្ជាអោយព្រះ **ចន្ទរាជា** លើកសួយសារអាករជាសត្វដំរីសទៅថ្វាយតាមលំលាប់ពីមុនរៀងមក ។ ដោយព្រះ **ចន្ទរាជា** ទ្រង់ប្រកែកមិនព្រមចំណុះសៀម សៀមលើកទ័ពចូលមកលុកលុយ ខេត្តអង្គរ ។ ព្រះអង្គទ្រង់កែនទ័ពហើយលើកទៅតទល់នៅត្រង់ស្ទឹងអង្គរ ត្រង់ភូមិមួយដែលជាប់ឈ្មោះហៅថា **សៀមរាប** រហូតដល់សព្វថ្ងៃ ជាអនុស្សាវរីយ៍នៃជោគជ័យរបស់ខ្មែរទៅលើសត្រូវ ឈ្លានពាន ។ ក្បួនរាជពង្សាវតារខ្លះបានបញ្ជាក់ថា ក្នុងការប្រយុទ្ធលើកនេះ ខ្មែរចាប់បានឈ្លើយ សង្គ្រាមអស់ជាច្រើន ។ ដើម្បីជាការសងសឹក នៅគ.ស.១៥៣០ ព្រះចៅសៀមទ្រង់បញ្ជាអោយ **ពញាអុង** លើកទ័ព ៩ ម៉ឺននាក់ មកវាយខ្មែរម្តងទៀត ។ ព្រះ **ចន្ទរាជា** ទ្រង់លើកទ័ពទៅតទល់គ្នានៅពោធិ៍សាត់ ។ នៅតាមផ្លូវពីលង្វែកទៅសមរភូមិ ព្រះអង្គទ្រង់ទតឃើញដើមពោធិ៍ ១ដើមងាប់យូរហើយ តែលាស់ឡើងវិញ ។ ដោយទ្រង់ឈ្វេងយល់ថា នេះជាប្រផ្នូលល្អ ព្រះអង្គទ្រង់យក ផ្កា ស្លា ម្លូ ទៀន ធូប ទៅធ្វើការបូជាហើយលើកទ័ពចេញទៅច្បាំងបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ដូចប្រាថ្នា ។ ឯទ័ពសៀមដែលមកឡើងគោកនៅត្រង់ឈូងសមុទ្រសៀមនោះ ក៏ត្រូវក្រឡាហោមខ្មែរវាយអោយបាក់ទ័ពថយទៅវិញដែរ ។ ប្រភពខ្លះបានបញ្ជាក់ទៀតថា ក្នុងចម្បាំងជើងគោកនៅពោធិ៍សាត់ មេទ័ពសៀមត្រូវស្លាប់អស់ជាច្រើនក្នុងចំណោមនោះមាន **ពញាអុង** ផងដែរ ដែលត្រូវព្រួញនៅលើខ្នងដំរី ឯពលទាហានស្លាប់អស់ពាក់កណ្តាល ដំរីងាប់អស់ច្រើន អាវុធយុទ្ធភ័ណ្ឌក៏ត្រូវរឹបអូសអស់សន្ធឹកសន្ធាប់ ។ ព្រះ**ចន្ទរាជា** ទ្រង់បញ្ជាអោយធ្វើបុណ្យថ្វាយព្រះភ្លើងព្រះសព **ពញាអុង** សាងព្រះវិហារបញ្ចុះធាតុ ឯដើមពោធិ៍ដែលរស់ឡើងវិញនោះទ្រង់ត្រាស់អោយហៅ**ព្រះពោធិមានបុណ្យ** រួចទ្រង់យាងត្រឡប់ចូលបន្ទាយលង្វែកវិញ ។

នៅគ.ស.១៥៣១ ឆ្លៀតពេលដែលខ្មែរកំពុងតែមានប្រៀបលើទ័ពសៀម ព្រះ**ចន្ទរាជា** ទ្រង់បានលើកទ័ពទៅរំដោះអាណាខេត្តខាងលិច ដែលត្រូវបាត់បង់ក្នុងរាជ្យមុនៗ ហើយទ្រង់វាយបានខេត្ត **បស្ចិមបុរី** មកវិញ ។

ចាប់ពីគ.ស. ១៥៥៦ នៅភូមាមានស្តេចមួយអង្គនាម **ឬាយិណោង** (Bayin Naung) បានលើកទ័ពចូលមកវាយសៀម ហើយដណ្តើមយកបានរាជធានី **អយុធ្យា** នៅគ.ស. ១៥៦៤ ។ ពួក សៀមបានបះបោរឡើងប្រឆាំងនឹងភូមាដែរ តែត្រូវបង្ក្រាបអោយរាបទាបទៅវិញអស់ និងត្រូវចាប់ជាឈ្លើយអស់ជាច្រើនថែមទៀត (13) ។ ឆ្លៀតយកឱកាសដែលសៀមកំពុងតែចុះទន់ខ្សោយយ៉ាងនេះ ព្រះ **ចន្ទរាជា** ទ្រង់បានលើកទ័ពចូលវាយសៀមនៅគ.ស.១៥៥៧ ហើយយកបានខេត្ត **ចន្ទបុរី** និងខេត្តផ្សេងៗ ទៀតនៅជិតៗ នោះ ។ ខ្មែរបានលើកទ័ពទៅវាយសៀមពីរលើកទៀត គឺនៅគ.ស.១៥៥៩ និង ១៥៦២ ហើយចាប់បានឈ្លើយជាច្រើននាំមកស្រុកវិញ ។

## ១.៣. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុបជាលើកដំបូង

នៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ" ភាគ ១ យើងបានលាតត្រដាងជូនអ្នកអាននូវមូលហេតុដែលនាំអោយជនជាតិអឺរ៉ុបធ្វើដំណើរមកកាន់ភូមិភាគអាស៊ីអាគ្នេយ៍យើងនេះរួចហើយ ។ យើងបានដឹងរួចហើយថា ក្រោយពីបានពង្រីងដំហាររបស់ខ្លួននៅជ្រោយម័លយូហើយ ពួកព័រទុយក័ល គឺជាជនជាតិអឺរ៉ុបដំបូងដែលបានចូលមកទាក់ទងនឹងខ្មែរនៅខាងចុងរជ្ជកាលរបស់ព្រះ **ចន្ទរាជា** ។ យ៉ាងណាមិញនៅគ. ស. ១៥៥៥មានបព្វជិតជាតិព័រទុយក័លខាងគណៈដូមិនិកាំង (dominicain) នាម Gaspar da Cruz ជាមិត្តភក្តិស្និទ្ធស្នាលរបស់លោក Albuquerque បានមកដល់ក្រុងលង្វែក ។ បព្វជិតអង្គនេះមានបំណងមកផ្សាយសាសនាគ្រិស្តនៅប្រទេសខ្មែរ ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យទទួលរាក់ទាក់ណាស់ ប៉ុន្តែបេសកកម្មរបស់លោកមិនបានទទួលផ្លែផ្កាដូចបំណងឡើយ ព្រោះប្រជារាស្ត្រខ្មែរនៅសម័យនោះកំពុងតែជាក់ចិត្តស៊ប់ទៅលើព្រះពុទ្ធសាសនា ហើយមិនព្រមលះបង់ព្រះរតនត្រ័យ ដើម្បីងាកទៅរកសាសនាដទៃទៀតឡើយ ។

ដោយលោកពុំបានសំរេចគោលបំណងយ៉ាងនេះហើយ លោកក៏ធ្វើដំណើរទៅកាន់ប្រទេសចិននៅឆ្នាំ ១៥៥៦ ។ ចំពោះរឿងនេះលោក Dauphin Meunier បានសរសេរថាលោកប្រញាប់វិលទៅវិញប្រហែលដើម្បីរាយការណ៍ប្រាប់ទៅនាយចៅហ្វាយរបស់លោកពីបេសកកម្មរបស់លោក ឬក៏ដោយលោកត្រូវចាត់អោយទៅបំពេញបេសកកម្មនៅទីដទៃទៀត ។

ក្នុងសម័យនោះ ក្រៅពីអ្នកផ្សាយសាសនា នៅមានអ្នកផ្សងព្រេងខ្លះទៀតដែលបានធ្វើដំណើរទស្សនាប្រទេសយើង ហើយបានកត់ត្រាទុកនូវហេតុការណ៍ដែលខ្លួនបានឃើញ ។ គឺកំណត់ហេតុទាំងនោះហើយ ដែលអ្នកប្រវត្តិសាស្ត្រ បានយកធ្វើជាឯកសារសំរាប់ឆ្លុះមើលសង្គមខ្មែរនៅស. វ. ទី ១៦ ។ អត្ថបទខាងក្រោមនេះរបស់លោក Diogo do Couto ជាតិព័រទុយក័លជាភស្តុតាងមួយស្រាប់ ។ លោកបានសរសេរជាអាទិ៍ថា : "ប្រមាណជាក្នុងឆ្នាំ១៥៥០ ឬ ១៥៥១ នៅពេលដែលព្រះមហាក្សត្រិយ៍នៃប្រទេសកម្ពុជាទ្រង់យាងទៅទាក់ដំរីនៅក្នុងព្រៃស្បាតនៅក្នុងរាជាណាចក្រនោះ បរិវាររបស់ព្រះអង្គដោយលុកចូលទៅក្នុងព្រៃដើម្បីដេញសត្វ ក៏ប្រទះនឹងសំនង់យ៉ាងសម្បើមៗដែលមានព្រៃគម្ពោតដុះពេញខាងក្នុង ហើយដែលគេមិនអាចកាប់ឆ្ការដើម្បីចូលទៅខាងក្នុងបាន ។ ដំណឹងនេះទ្រង់ជ្រាបដល់ព្រះរាជា ព្រះអង្គក៏យាងទៅដល់ទីនោះ ហើយទ្រង់ទតឃើញនូវវិសាលភាព និងកំពស់នៃជញ្ជាំងខាងក្រៅ ទ្រង់បញ្ជាអោយកាប់ឆ្ការ និងដុតព្រៃភ្លាមមួយរំពេច ដើម្បីទ្រង់បានទតឃើញខាងក្នុង ។ ក្រោយដែលព្រៃគម្ពោតត្រូវបានបោសសំអាតអស់ហើយព្រះរាជាក៏ទ្រង់យាងទតគ្រប់សព្វទីកន្លែងហើយ ទ្រង់មានសេចក្តីស្ញប់ស្ញែងចំពោះទំហំធំធេងនៃសំនង់ទាំងនោះ ។ហើយដោយហេតុនោះ ព្រះអង្គទ្រង់ត្រាស់

បញ្ជាអោយនាំពួកបរិវារទៅគង់នៅទីនោះវិញ (14) ។ សេចក្តីនៃអត្ថបទនេះ គឺចង់ដៅចំពោះការរកឃើញឡើងវិញរូវប្រាសាទសិលានៅតំបន់អង្គរដែលត្រូវបោះបង់ចោលអស់រយៈពេលជាងមួយសតវត្សមកហើយ ។

ក្រៅពីថ្វីព្រះហស្តក្នុងចំបាំងរំដោះ និងការពារទឹកដីខ្មែរ និងព្រះរាជូបត្ថម្ភយ៉ាងកក់ក្តៅក្នុងពុទ្ធសាសនា ព្រះ **ចន្ទរាជា** ទ្រង់បានយកព្រះហឫទ័យទុកដាក់យ៉ាងខ្លាំងក្នុងវិស័យផ្សេងៗទៀត ដូចជាវិស័យអក្សរសាស្ត្រនិងសេដ្ឋកិច្ចជាដើម ។គេដឹងថាក្រោយដែលព្រះអង្គបានឡើងគ្រងរាជសម្បត្តិហើយព្រះអង្គចាត់អោយគេដើរស៊ើបរកពួកអ្នកបណ្ឌិតមកចិញ្ចឹមទំនុកបំរុងទុកជាគ្រឹះនៃប្រទេសជាតិ ។ នេះជាគុណសម្បត្តិមួយដែលគេកម្រឃើញមានក្នុងសន្តានចិត្តរបស់អ្នកដឹកនាំជាតិក្នុងសម័យនោះ ដែលច្រើនតែព្យាយាមធ្វើទុកបុកម្នេញចំពោះពួកបញ្ញវន្ត ពួកខ្លាំងពូកែ មានអ្នកសិល្បជាដើម ។ ក្នុងវិស័យសេដ្ឋកិច្ច ព្រះអង្គទ្រង់បង្គាប់អោយកាប់ឆ្ការព្រៃដើម្បីយកដីពង្រីកទំហំស្រែចំការនិងជួយទំនុកបំរុងយ៉ាងខ្លាំងចំពោះការស្ទូរយកដែក ។

សូមបន្ថែមថា ក្នុងវិស័យគ្រប់គ្រងរដ្ឋ **ព្រះចន្ទរាជា** ទ្រង់បានតាំងព្រះរាជបុត្រច្បងនាម **រាមាធិបតី** ជាឧបយោរាជ និងព្រះរាជបុត្របន្ទាប់នាម **បរមេន្ទរាជា** ជាមហាឧបរាជ ។ ក្បួនរាជពង្សាវតារខ្លះបានបញ្ជាក់ថា **ព្រះរាមាធិបតី** ដោយយកបុត្រីឯងជាភរិយា ក៏ត្រូវព្រះធរណីស្រូបទៅ ។ ក្រៅពីនេះ ព្រះអង្គទ្រង់បានតាំងស្តេចក្រាញ់ ៥ អង្គ គឺចៅហ្វាយស្រុកខេត្តអាសន្ទុក ១ ខេត្តពោធិ៍សាត់១ ខេត្តត្បូងឃ្មុំ ១ ខេត្តបាភ្នំ ១ ខេត្តទ្រាំង ១ ។ ក្បួនខ្លះទៀតបានបន្ថែមថា ក្នុងរាជ្យរបស់ព្រះអង្គ ព្រះអង្គទ្រង់ព្រះពស្ត្រ ៨ហត្ថ នាម៉ឺនពាក់ស្បៃ ៨ហត្ថដែរ ទូលឆ្លើយត្រូវថាព្រះបាទអម្ចាស់ ជិះគ្រែកាន់ផ្លិតស្លឹកត្នោតចូលគាល់ ។

**ព្រះចន្ទរាជា** ទ្រង់សោយទិវង្គតនៅក្រុងលង្វែកនៅគ.ស.១៥៦៦ ។ ព្រះចេតិយតំកល់ព្រះអដ្ឋិធាតុរបស់ព្រះអង្គស្ថិតនៅលើភ្នំព្រះរាជទ្រព្យសព្វថ្ងៃ ។

## ២. ព្រះបាទបរមរាជាទី ៤ (១៥៦៦-១៥៧៦) និងការរំដោះអាណាខេត្តខាងលិច

ក្រោយពីព្រះ**ចន្ទរាជា** សោយទិវង្គតទៅ ព្រះមហាឧបរាជ ដែលត្រូវជាព្រះរាជបុត្របន្ទាប់នាម **បរមរាជា** ឡើងសោយរាជ្យស្នងព្រះបិតា ដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះសម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។

ក្បួនរាជពង្សាវតារខ្លះ បានអោយពត៌មានថា ព្រះបាទ **បរមរាជាទី ៤** មានបុត្រា ៤អង្គគឺ :

១. **ព្រះសត្ថា** (ប្រសូតនៅគ.ស.១៥៣៩)

២. **ព្រះស្រីសុរិយោពណ៌** (បុត្រ **ព្រះម្ចាស់កែសរមាលា** ប្រសូតនៅគ.ស. ១៥៥៦)

៣. **ពញាន្ទ** (បុត្រ **ព្រះម្ចាស់កែសរមាលា** ប្រសូតនៅគ.ស. ១៥៥៨)

៤. **ចៅពញាអន** (បុត្រ **ព្រះម៉ែនាងខន** ប្រសូតនៅគ.ស. ១៥៦៣)

ប្រភពដដែលបានអោយដឹងថា **ព្រះស្រីសុរិយោពណ៌** បានយកបុត្រីរបស់ **ពញាយសរាជា** (មិនបានសោយរាជ្យ) នាម**ជាតិក្សត្រី** ហើយមានបុត្រនាមព្រះ**ជ័យចេស្តា**។

## ២.១. ទំនាក់ទំនងជាមួយសៀម និងការរំដោះ អាណាខេត្តខាងលិច

ឆ្លៀតឱកាសដែលប្រទេសសៀមកំពុងតែទន់ខ្សោយដោយការវាយលុកពីសំណាក់ស្តេចភូមានាម **បាយិណោង** (Bayin Naung) ដែលបានវាយយករាជធានី **អយុធ្យា** នៅគ.ស.១៥៦៤នោះ ព្រះបាទ **បរមរាជាទី ៤** ទ្រង់បានបន្តកិច្ចការរបស់ព្រះបិតាព្រះអង្គ គឺការវាយរំដោះយកអាណាខេត្តខាងលិចមកវិញថែមទៀត ។

ចំពោះរឿងនេះ ឯកសារសៀម (8) បានអោយពត៌មានថា : "ក្នុងរជ្ជកាលព្រះ **មហាធម្មរាជា** ព.ស.២១១២ (គ.ស.១៥៦៨) ដែលជាវេលាក្រុងស្រីអយុធ្យាត្រូវបាត់បង់ដោយភូមាវាយ ខ្មែរបានវាយបន្ថែម ព្រោះគ្រានោះភូមាកៀរមនុស្សយកទៅជាច្រើន ។ ស្រុកទេសក៏យ៉ាប់យឺនមិនមានកម្លាំងដូចពីមុន ព្រះ **បរមរាជា** ស្តេចក្រុងកម្ពុជាលើកកងទ័ពប្រមាណ២០ ០០០នាក់ ចូលមកវាយក្រុងស្រីអយុធ្យា លើកចូលមកបានដល់ជាយក្រុង តែពួករេហ៍ពលក្នុងកងទ័ពខ្មែរ កាលថៃបាញ់មេទ័ពមុខរបស់ខ្មែរស្លាប់ហើយ កងទ័ពខ្មែរក៏ត្រឡប់ទៅកៀរមនុស្សនៅខេត្តតាមផ្លូវជាឈ្លើយអស់ជាច្រើន "។ ឯរាជពង្សាវតារខ្មែរបានអះអាងថា ទ័ពខ្មែរបានចូលលុកក្រុង **អយុធ្យា** តែយកមិនបាន ក៏ថយមកកៀរគ្រួសៀមមកជាច្រើន។ ដូច្នេះ ទោះបីមានល្អៀងបន្តិចបន្តួចក៏ដោយ ក៏ឃើញថាប្រភពសៀម និងប្រភពខ្មែរបាននិយាយស្របគ្នា ចំពោះព្រឹត្តិការណ៍ដ៏សំខាន់នេះដែរ ។

នៅគ.ស.១៥៦៩ ស្តេចភូមានាម **បាយិណោង** លើកទ័ពចូលវាយសៀមយកបានរាជធានី **អយុធ្យា**ម្តងទៀត ហើយដាក់ប្រទេសសៀមជាចំណុះអស់រយៈពេល១៥ឆ្នាំ។ ឆ្លៀតឱកាសមានវឹកវរនេះ នៅគ.ស.១៥៧០ គឺនៅពេលដែលព្រះបាទ **បរមរាជា** យាងទៅគង់នៅតំបន់អង្គរត្រង់កំពង់ក្រសាំង ខ្មែរបានលើកទ័ពលុកចូលទៅយកបានខេត្ត **នគររាជសីមា** ហើយដាក់មន្ត្រីខ្មែរអោយនៅឈរត្រួតត្រាទីនោះ ។

ចំពោះទំនាក់ទំនងខ្មែរ - សៀម ឯកសារសៀម(8) បានសរសេរជាបន្ថែមទៀតថា : " ក្នុង ព.ស. ២១១៨ (គ.ស.១៥៧៤) ខណៈដែលសម្តេចព្រះ **មហាធម្មរាជា** និងសម្តេចព្រះ **នរេសូរ** លើ

ទ័ពទៅជួយព្រះចៅ **មហាធម្មរាជា** វាយស្រុក **វៀងចន្ទន៍** ព្រះចៅក្រុងកម្ពុជាលើកទ័ពជើងទឹកមកវាយ **អយុធ្យា** ម្តងទៀត តែជាចៃដន្យ កងទ័ពថៃត្រឡប់មកវិញ ព្រះសម្តេច **នរេសូរ** ប្រឈួនកើតគ្រុនសន្និ ស្តេចត្រឡប់មកទាន់កងទ័ពខ្មែរល្មម ថៃវាយកងទ័ពខ្មែរអោយថយម្តងទៀត " ។ ត្រង់ការវាយលុករបស់ភូមាទៅលើស្រុក **វៀងចន្ទន៍** នេះ យើងមានសេចក្តីបញ្ជាក់ពីឯកសារលាវ (15) ដែលបានចែងថា នៅគ.ស.១៥៧៤ ទ័ពភូមាក្រោមបញ្ជាការរបស់ស្តេច Bereng Naung (Bayin Naung) បានចូលវាយលុករាជធានី **វៀងចន្ទន៍** ជាលើកទី៣ ។ មេទ័ពលាវឈ្មោះ Phaya - Sèn-Soulinthara ដែលបានតាំងខ្លួនថា ជារជ្ជទាយាទពីមុនមក ចង់ធ្វើសង្គ្រាមផ្ទក់ដើម្បីរំដោះ **វៀងចន្ទន៍** ប៉ុន្តែនៅពេលនោះពួកលាវបាក់បែកគ្នាខ្លាំង គំរោងការរបស់លោកក៏ត្រូវទទួលបរាជ័យទៅ ។ ចំពោះចម្បាំងខ្មែរ-សៀមលើកនេះ (គ.ស.១៥៧៤) រាជពង្សាវតារខ្មែរបាននិយាយថា ខ្មែរស៊ើបការណ៍ដឹងថាស្តេចសៀមរវល់តែធ្វើចម្បាំងជាមួយលាវ (ជួយភូមាដោយបង្ខំ ?) ទុកកូនអោយនៅថែរក្សានគរក៏លើកទ័ពទៅវាយសៀមទៀត ។ ទ័ពខ្មែរ ចិនត្រូវនាំដោយ **ចៅពញាចិនចាន់តុក** បានប្រើកលល្បិចគឺវាយស្រុកតូចៗពី **ចន្ទបុរី** ដល់ **ធនបុរី** ដើម្បីអោយស្តេចសៀមចេញជួយទើបលុកយកក្រុង**អយុធ្យា** ។ បើដូច្នេះ អាណាខេត្តខាងលិចទាំងមូលពី **នគររាជសីមា** ចុះមករហូតដល់ **ចន្ទបុរី** ត្រូវទ័ពខ្មែររំដោះបានទាំងស្រុង ។ កាលណោះដោយត្រូវភូមានិងខ្មែរកៀបសង្កត់ខ្លាំងពេក ស្តេចសៀមត្រូវបង្ខំចិត្តធ្វើសន្ធិសញ្ញាចងស្ពានមេត្រីជាមួយខ្មែរនៅគ.ស.១៥៧៤នោះ ហើយបានថ្វាយចំពោះព្រះមហាក្សត្រខ្មែរនូវខេត្ត **នគររាជសីមា បសុិមបុរី ចន្ទបុរី** ។

## ២.២. ទំនាក់ទំនងជាមួយលាវ

ចំពោះទំនាក់ទំនងខ្មែរ - លាវនេះ យើងមានតែឯកសាររាជពង្សាវតារខ្មែរ ចំណែកឯកសារលាវដែលសរសេរជាភាសាលាវក្តី (16) ជាភាសាបារាំងក្តី (15) ពុំមានផ្តល់ពត៌មានអ្វីបន្តិចបន្តួចសោះ ។ នេះជាហេតុនាំអោយយើងមានចំងល់ ចេះតែឆ្ងល់ថាចុះហេតុអ្វីបានជារាជពង្សាវតារលាវមិនព្រមនិយាយពីព្រឹត្តិការណ៍ដ៏សំខាន់នេះ ។ តើនេះជាការភ្លេចភ្លាំងដោយអចេតនា ឬក៏ជាការបំភ្លេចចោលដោយចេតនាព្រោះតែខ្លាចអាម៉ាស់ ?

រាជពង្សាវតារខ្មែរច្រើនក្បួនបាននិយាយថា នៅគ.ស.១៥៧២ ស្តេចលាវនគរ **លានជាង** ទ្រង់ត្រាស់បញ្ជាអោយនាម៉ឺន២នាក់ ពល ១០០០នាក់ មកបបួលខ្មែរប្រជល់ដំរីដាក់នគរ គឺថាបើដំរី នគរណាចាញ់ នគរនោះត្រូវចំណុះនគរម្ខាងទៀតដែលមានដំរីឈ្នះ ។ កាលណោះ ព្រះបាទ **បរម រាជាទី៤** គង់នៅកំពង់ក្រសាំងនាតំបន់អង្គរ ព្រះអង្គទ្រង់យល់ព្រមចំពោះសំនើរបស់លាវ ។ ការប្រយុទ្ធរវាងដំរីទាំងពីរក៏ប្រព្រឹត្តទៅនៅក្បែរក្រុងលង្វែក ។ រាជពង្សាវតារខ្មែរក្បួនខ្លះបានបញ្ជាក់ថា ដំរីលាវមានកំពស់

ដល់៨ហត្ថ(៤ម.) ឯដំរីខ្មែរមានកសំពស់តែ៧ហត្ថ (៣,៥០ម.)។ ទោះបីចាញ់ប្រៀប ដំរីលាវបន្តិចក៏ដោយ ក៏ដំរីខ្មែរបានទទួលជោគជ័យយ៉ាងត្រចះត្រចង់។ ខ្មែរបានឃាត់ពួកលាវខ្លះ (១០០នាក់) ទុកអោយតែនាម៉ឺន២នាក់នាំដំណឹងទៅថ្វាយស្តេចលាវហើយអោយនាំបណ្ណាការមកថ្វាយស្តេចខ្មែរ។

ស្តេចលាវខ្ញាល់ខ្លាំង បញ្ជាអោយលើកទ័ពចូលវាយខ្មែរទាំងផ្លូវគោក និងទាំងផ្លូវទឹក។ ទ័ពលាវចូលចោមវាយបន្ទាយខ្មែរនៅ **អាសន្ទុក** ហើយចាប់បានខ្មែរជាឈ្លើយអស់ច្រើន។ ស្តេចលាវ និងស្តេចខ្មែរលើកទ័ពតទល់គ្នាផ្ទាល់ព្រះអង្គ។ ស្តេចលាវចាញ់។ ខ្មែរចាប់លាវបានជាឈ្លើយអោយ១០០០នាក់នៅត្រង់ **ឈាយណំ** សល់ពីនេះអោយទៅនៅខេត្តខាងត្បូង និងខាងលិច។ ខាងជើងទឹកក៏ខ្មែរមានជ័យជំនះលើទ័ពលាវដែលស្ថិតនៅក្រោមបញ្ជាការរបស់មហាឧបរាជលាវ។ ព្រះ**បរម រាជាទី៤** ទ្រង់យាងមកលង្វែកវិញ ទ្រង់ចាត់អោយធ្វើបុណ្យឆ្លងជោគជ័យ អោយលាវ ៨០០នាក់ទៅនៅស្រុក **ធានំ** អោយ ៥០០នាក់នៅសំរាប់ថែវត្តភ្នំពេញ។ ពួកនេះខ្មែរហៅថា លាវបាក់ទូក។

នៅគ.ស.១៥៧៤ ក្នុងបំណងសងសឹកអោយបាន លាវគិតលើកទ័ពមកវាយខ្មែរទៀត គាប់ជួនពេលនោះភូមានាំសៀមចូលវាយ **ខៀវចន្ទន៍** ទៀតហើយដោយមានភ្លៀងធ្លាក់ខ្លាំងផង ទ័ពលាវ ក៏ដកថយទៅវិញអស់។ ត្រង់នេះ ក្បួនរាជពង្សាវតារខ្លះថា លាវវាយចាញ់ខ្មែរទៀត ឯឧបរាជបានរត់រួចចូលទៅស្រុកវិញ។

ព្រះ **បរមរាជាទី ៤** ក៏ជាព្រះមហាក្សត្រមួយអង្គដែលបានជួយឧបត្ថម្ភព្រះពុទ្ធសាសនាដែរ។ ព្រះអង្គទ្រង់អោយសាង **វត្តព្រះឥន្ទទេព** នៅក្នុងបរិវេណបន្ទាយលង្វែក។

ព្រះអង្គទ្រង់សោយទិវង្គតនៅគ.ស. ១៥៧៦។ ប៉ុន្តែ បើតាមឯកសារសៀមព្រះអង្គត្រូវក្ស័យព្រះជន្មនៅគ.ស. ១៥៧៤ម្ល៉េះ គឺកាលដែលព្រះអង្គលើកទ័ពទៅវាយក្រុង **អយុធ្យា** នោះ។

## ២.៣. ទំនាក់ទំនងជាមួយជនជាតិអឺរ៉ុប

តាមកំណត់ហេតុរបស់បព្វជិត Gabriel de San Antonio គេដឹងថាព្រះ **បរមរាជាទី ៤** ដោយទ្រង់ឈ្វេងយល់ថា សកម្មភាពខាងជំនួញនឹងកើតមានឡើងបន្ទាប់ពីការមកដល់របស់ពួកបព្វជិត ព្រះអង្គក៏ទ្រង់បានអំពាវនាវសុំអោយអង្គការកណ្តាលនៅ Malacca បញ្ជូនអ្នកផ្សាយសាសនាមកកាន់ប្រទេសព្រះអង្គ។ ដោយហេតុនោះ គេឃើញបព្វជិតពីរអង្គបាននិមន្តមកកាន់ប្រទេសខ្មែរ គឺបព្វជិត Lopo Cardoso និង Joao Madeira គេមិនដឹងច្បាស់ថាបព្វជិតទាំងពីរអង្គបាននិមន្តមកក្នុងឆ្នាំណាទេ តែបើតាមហេតុការណ៍ដែលមានតមកទៀត នោះឃើញថា បព្វជិតទាំងពីរអង្គត្រូវនិមន្តមកដល់លង្វែកមុនគ.ស. ១៥៧០ (19)។

អ្នកនិពន្ធជាតិអឺរ៉ុបជាច្រើនបានអះអាងថា នៅគ.ស.១៥៧០ អ្នកផ្សាយសាសនាព័រទុយក័លម្នាក់បានរកឃើញប្រាសាទតំបន់អង្គរ ហើយបានកត់ទុកក្នុងកំណត់ហេតុរបស់លោក ។ គេមិនបានបញ្ជាក់ពីឈ្មោះរបស់អ្នកផ្សាយសាសនារូបនេះទេ តែបើតាមស្មានមើលទៅ គឺមានតែបព្វជិត Cardoso ឬ Madeira ប៉ុណ្ណោះ ។

ដោយហេតុថាវត្តមានរបស់អ្នកផ្សាយសាសនាពុំបានញ៉ាំងជំនួញអោយមានសកម្មភាពដូចព្រះបំណងនោះ ព្រះរាជាក៏ទ្រង់ចាប់ផ្តើមធ្វើទុក្ខបុកម្នេញលើរូបពួកបព្វជិត ។ បព្វជិត Sylvestre d'Acevedo បានមកជំនួសបព្វជិត Madeira ឯបព្វជិត Cardoso ក៏ត្រូវត្រឡប់ទៅវិញ ។ បន្ទាប់មក មានបព្វជិតពីរអង្គបាននិមន្តមកដល់ទៀត តែគង់នៅមិនយូរប៉ុន្មានក៏ត្រឡប់ទៅវិញទៀត ។ ដូច្នេះក្នុងរយៈពេលយ៉ាងយូរ បព្វជិត Sylvestre d'Acevedo បានស្ថិតនៅក្នុងប្រទេសខ្មែរ តែមិនអាចផ្សាយ សាសនាគ្រិស្តអោយជ្រួតជ្រាបចូលក្នុងសង្គមខ្មែរបានឡើយ (19) ។

# គ. ការបែកបាក់ក្រុងលង្វែកនិងផលវិបាក

## ១. ព្រះបាទសត្ថាទី ១ (១៥៧៦-១៥៩៥)

ក្រោយពីព្រះបិតាសោយទិវង្គតទៅព្រះរាជបុត្រច្បងនាម **សត្ថា**ឡើងសោយរាជ្យស្នងដោយមាននាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះបរមរាជាធិរាជរាមាធិបតី** ។ អ្នកប្រវត្តិសាស្ត្រនិយមហៅស្តេចអង្គនេះថា **ព្រះសត្ថាទី ១** ឬ **ព្រះបរមរាជាទី ៥** ។ ព្រះអង្គទ្រង់អភិសេកអ្នកនាង **ពៅ** ជាអគ្គមហេសីនាម **សម្តេចព្រះតគចតីស្រីចក្រពត្តិរាជ** និងអភិសេកព្រះអនុជបន្ទាប់នាម **ស្រីសុរិយោពណ៌** ជាមហាឧបរាជ ។ កាលគ.ស.១៥៧៤ បានសម្ភពនឹងអគ្គមហេសី នូវបុត្រនាមព្រះ **ជ័យជេដ្ឋា** ហើយកាលសោយរាជ្យបាន ៤ឆ្នាំ (១៥៨០) បានសម្ភពរាជបុត្រមួយអង្គទៀតនាម ចៅ**ពញាតន់** ។ ព្រះអង្គមានម្នាងលាវមួយទៀតឈ្មោះអ្នកម្នាង **ពេជមេលាច** ហើយបានសម្ភពនឹងអ្នកម្នាងនេះនូវបុត្រនាម **ចៅពញាញោម** ។ ឯព្រះអនុជមានព្រះរាជបុត្រពីរអង្គនាមព្រះ**ជ័យចេស្តា** ១អង្គ ព្រះ **ឧទ័យ** ១អង្គ ។

### ១.១. ទំនាក់ទំនងជាមួយសៀម

បើតាមឯកសារសៀម **ព្រះសត្ថា** បានលើកទ័ពចូលវាយក្រុង **ពេជ្របុរី** បីដងក្នុងចន្លោះ ព.ស. ២១១៨ ដល់ ២១២៤ (គ.ស. ១៥៧៤ -១៥៨០) ។ ទីបំផុតចូលវាយ**មឿងពេជ្របុរី**បាន បោសសំអាតមនុស្សយកទៅទៀត ។ ដែលឯកសារសៀមថាដូច្នេះ ព្រោះបានចាត់ទុកថា **ព្រះបរម រាជាទី ៤**

បានសោយទិវង្គតតាំងពីគ.ស. ១៥៧៤ ដូចយើងបានជំរាបរួចមកហើយ ។ បើតាមរាជពង្សាវតារខ្មែរខ្លះ **ព្រះសត្ថា** ទ្រង់បានលើកទ័ពទៅវាយក្រុង **អយុធ្យា** ហើយចាប់បានឈ្លើយសៀមជាច្រើន ទំនងជាក្នុង គ.ស.១៥៧៩ ឬ១៥៨០ ។ មានក្បួនរាជពង្សាវតារខ្លះទៀតនិយាយថា នៅគ.ស.១៥៨០ នោះប្រទេសសៀមនៅជាចំណុះរបស់ស្តេចភូមានាម Bayin Naung នៅឡើយ ។ ព្រះរាជបុត្រស្តេចសៀមនាម**នរេសូរ** បានទៅនៅបំរើស្តេចភូមានៅក្រុង**ហង្សាវតី** ។ ថ្ងៃមួយ**នរេសូរ** បានលើកដៃថ្វាយបង្គំស្តេចភូមា ស្តេចភូមាទ្រង់ទតឃើញមានព្រះហស្តប្អូន ទ្រង់ជ្រាបថាជាអ្នកមានបុណ្យ ក៏រកកលសម្លាប់ ។ **នរេសូរ** ដឹងខ្លួនរត់មកក្រុង**អយុធ្យា** វិញ ។ ពួកភូមាដេញតាម (17) ។ ព្រះចៅសៀមទ្រង់ផ្ញើសារមកសុំជំនួយពីខ្មែរ ។ ដោយទ្រង់គោរពតាមសន្ធិសញ្ញាសន្តិភាពខ្មែរ-សៀម កាលពីគ.ស.១៥៧៤ ព្រះបាទ **សត្ថាទី១** ទ្រង់បញ្ជាអោយមហាឧបរាជ **ស្រីសុរិយោពណ៌** លើកទ័ពទៅជួយតាមសំណូមពរ ។ ទ័ពខ្មែរបានជួយច្បាំងព្រះ **នរេសូរ** រហូតបានជ័យជំនះលើភូមា ។ លុះលើកទ័ពមកវិញ ព្រះ **នរេសូរ** ទ្រង់ទតឃើញព្រះ **ស្រីសុរិយោពណ៌** គង់សំយុងព្រះបាទ ពុំបានគង់ក្រាបដូចអ្នកផង ក៏ទ្រង់ព្រះពិរោធណាស់ ។ ម្យ៉ាងទៀតព្រះ **នរេសូរ** ទ្រង់បានកែនរាស្ត្រក្នុងខែត្រ ដែលត្រូវឡើងមកស្តេចខ្មែរ ។ ព្រះ **ស្រីសុរិយោពណ៌** ទ្រង់ខ្ញាល់ពីរឿងនេះខ្លាំងណាស់ ហើយលើកទ័ពត្រឡប់ចូលនគរវិញ ។ ចំពោះរឿងនេះ មានឯកសារខ្លះសរសេរថា : "ប៉ុន្តែជ័យជំនះនេះពុំបានធ្វើអោយសៀមអបអរសាទរឡើយ ផ្ទុយទៅវិញជ័យជំនះនេះបណ្តាលអោយអាប់កិត្តិយសកងទ័ពសៀម ហើយពិសេសអាប់កិត្តិយសរបស់រាជបុត្រស្តេចសៀមនាមព្រះ **នរេសូរ** ។ ចាប់តាំងពីពេលនោះមក ព្រះ **នរេសូរ** តែងមានគំនុំចង់យកស្រុកខ្មែរជាចំណុះដោយរំលោភលើកិច្ចចរចាក្នុងឆ្នាំ១៥៧៦ " (18) ។ គួរគប្បីជ្រាបថា ចំពោះជំនួយទ័ពរបស់ខ្មែរខាងលើនេះ ឯកសារសៀមពុំឃើញមាននិយាយផងទេ ។

នៅគ.ស. ១៥៨១ ខ្មែរបានលើកទ័ពទៅវាយរំដោះបាន **នគររាជសីមា ចន្ទបុរី** និង **នគរនាយក** ។ ឯកសារសៀមថា សម្តេចព្រះ **នរេសូរ** បានលើកទ័ពទៅតស៊ូ ។ ឯកសារខ្មែរថា ព្រះ **នរេសូរ** វាយយកបាន **នគររាជសីមា** វិញនៅគ.ស.១៥៨២ គឺស្របនឹងឯកសារសៀមដែរ តែឯកសារសៀមគ្មានបានបញ្ជាក់ថាយកបានខែត្រណាទេ ។ ឯកសារសៀមនិយាយថា កាលសម្តេចព្រះ **នរេសូរ** ប្រកាសឯករាជ្យរំដោះប្រទេសសៀមពីចំណុះភូមា (គ.ស.១៥៨៤ ?) ទ្រង់មានកិត្តិសព្ទល្បីល្បាញ ព្រះ**សត្ថា** ក្រែងថាសៀមនឹងត្រឡប់មកសងសឹកកម្ពុជា ទើបតែងព្រះរាជមេត្រីសារភាពទទួលខុសព្រមចំណុះក្រុង **ស្រីអយុធ្យា** (8) ។ ត្រង់ចំណុចនេះ ឯកសារខ្មែរគ្មាននិយាយដល់ឡើយ ។ យើងគ្រាន់តែឆ្ងល់ថា តើការពិតស្ថិតនៅត្រង់ណា បើកាលណោះខ្មែរអាចជួយសៀមច្បាំងឈ្នះភូមា ថែមទៀត ហេតុដូចម្តេចក៏ត្រឡប់ជាខ្លាចសៀមវិញ ? ។

គួរគប្បីជ្រាបថា នៅប្រទេសភូមាឯណោះ ស្តេចនាម Nanda Bayin បានឡើងសោយរាជ្យស្នងព្រះបិតានាម Bayin Naung ពីគ.ស.១៥៨១ ដល់ ១៥៩៩ ។ ស្តេចអង្គនេះជាស្តេចមានមហិច្ឆិតា ទ្រង់បានបន្តនយោបាយវាតទីកដីរបស់ព្រះបិតាព្រះអង្គ ។ ដោយហេតុនោះហើយបានជានៅគ.ស.១៥៨៥ ព្រះអង្គបានលើកទ័ពចូលវាយក្រុង **អយុធ្យា** ម្តងទៀត ។ ឯកសារសៀមថា ព្រះ**សត្ថា** ជឿថា ក្រុង **អយុធ្យា**គង់នឹងបាត់បង់ដោយភូមាដូចគ្រាមុន ទ្រង់បានផ្តាច់មេត្រីភាពហើយលើកទ័ពចូលវាយស្រុក **បសិ្ចមបុរី** ។ ត្រង់នេះ ឯកសារខ្មែរថា ទ័ពខ្មែរយកបាន **បសិ្ចមបុរី នគររាជ** និង **នគរនាយក** ។ លុះសៀមលើកទ័ពមក ខ្មែរក៏ថយសិន ហើយដោយមានដំណឹងថា **សម្តេចព្រះតគចតី** ប្រឈួន ព្រះ**សត្ថា** ក៏លើកទ័ពត្រឡប់មកបន្ទាយលង្វែកវិញ ។ ឯកសារសៀមបាននិយាយថា : “សម្តេចព្រះ**នរេសូរ** ទ្រង់ខ្វាល់នឹងព្រះ **សត្ថា** ដូច្នេះក្នុងព.ស.២១៣០ (គ.ស. ១៥៨៦) កាលភូមាលើកទ័ពត្រឡប់ទៅវិញហើយ ទើបស្តេចលើកទ័ពទៅវាយក្រុងកម្ពុជា វាយបានស្រុក **បាត់ដំបង** និងស្រុក **ពោធិ៍សាត់** ហើយលើកទ័ពត្រឡប់មកព្រះនគរវិញ ព្រោះខ្វះស្បៀងអាហារ ”(8) ។ ត្រង់នេះ ឯកសារខ្មែរខ្លះនិយាយថា : “សៀមក៏ចាប់ធ្វើសង្គ្រាមទន្ទ្រានទឹកដីខ្មែរដោយគ្មានលេសអ្វីឡើយ ” (18) ។ ឯក្សួនរាជពង្សាវតារខ្មែរខ្លះនិយាយថា នៅគ.ស. ១៥៨៤ (គ.ស. ១៥៨៦ សមជាងព្រោះពេលនេះភូមាថយទៅវិញហើយ) ព្រះ **នរេសូរ**លើកទ័ពមកវាយខ្មែរ ខ្មែរបានលើកទ័ពទៅប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅបាត់ដំបងរួចនៅស្ទឹង**អំពង់ធ្លាក់** តែទន់ដៃជាងក៏ដកថយសិន ។ សៀមវាយយកបាន **បន្ទាយមានជ័យ**រួចយកបាន **បន្ទាយបរិបូណ៌** ទៀត ។ ព្រះ **ស្រីសុរិយោពណ៌** នាំទ័ពថយចូលក្នុង**បន្ទាយលង្វែក** ។ រាជពង្សាវតារខ្មែរខ្លះបញ្ជាក់ថា ក្នុងចម្បាំងលើកនោះសៀមមានទ័ពចំនួន ១០០ ០០០នាក់ ដំរី ៨០០ និងសេះ ១៨៥០ ។ ទោះបីមានទ័ពច្រើនសន្ធឹកសន្ធាប់និងខ្លាំងពូកែយ៉ាងនេះក៏ដោយ ក៏សៀមពុំអាចវាយលុកយកបានបន្ទាយលង្វែកឡើយ ។ ក្រោយពីឡោមព័ទ្ធបន្ទាយនេះអស់រយៈពេល ៣ ខែ ដោយខ្វះស្បៀងអាហារ និងដោយត្រូវជម្ងឺឆ្លងរាតត្បាតស្លាប់អស់ច្រើនផង សៀមក៏ដកទ័ពថយទៅវិញ ព្រោះខ្មែរដឹងចំណុចខ្សោយរបស់សៀមហើយនាំគ្នាចេញពីបន្ទាយទៅវាយលុកយ៉ាងខ្លាំង ។ មានប្រវត្តិវិទូខ្លះ (9) ថាមានកងទ័ពខ្មែរមួយមកពីក្រៅជួយធ្វើអន្តរាគមន៍កំចាត់សៀមទៅវិញ ។

ឯកសារខ្មែរខ្លះនិយាយថា ទ័ពសៀមឈឺស្លាប់ច្រើន គឺបណ្តាលមកពីបិសាចធ្វើ ។ ព្រះ **នរេសូរ** បានចាត់អោយសាកសួរខ្មែរ ក៏បានដឹងថាមានទេវរក្ស ១៣ អង្គជួយថែរក្សានគរខ្មែរ ។ ម្យ៉ាងទៀត មុននឹងរត់ដកខ្លួនទៅ សៀមបានប្រើឧបាយកលបាញ់ប្រាក់ដួងជាច្រើនចូលក្នុងគុម្ពឫស្សី ដែលជារបងយ៉ាងមាំមួនជាទីបំផុតសំរាប់ការពារបន្ទាយលង្វែក ។

ក្រោយមក ព្រះចៅសៀមបានចាត់ចារបុរសពីរនាក់ ចូលមកធ្វើវិទ្ធង្សនាបង្កើតអោយមានចលាចលក្នុងផ្ទៃក្នុងរបស់ខ្មែរៈមហាតលិកសៀមពីរនាក់បានក្លែងធ្វើជាអ្នកបួសនាម **តិបញ្ញោ** និង **សុប្បញ្ញោ**

ចូលមកធ្វើពិធីដកសិល្បសាស្ត្រដែលបញ្ចុះក្នុងរូបទេវរក្ស ។ **សុច្បញ្ញោ** ប្រើមន្តអាគមធ្វើអោយអ្នកស្រុកឈឺ **តិចញ្ញោ** ជាអ្នកដោះអោយជាសះស្បើយឡើងវិញ ។

នៅប្រមាណជា គ.ស. ១៥៨៦ ព្រះបាទ **សត្ថាទី១** ទ្រង់សព្វព្រះរាជហឫទ័យដាក់រាជ្យ ថ្វាយទៅព្រះរាជបុត្រច្បងនាមព្រះ **ជ័យជេដ្ឋា** ដែលមានព្រះជន្មទើបបាន១១វស្សា អោយឡើងសោយរាជ្យស្នងព្រះអង្គដោយមានព្រះនាមសំរាប់រាជ្យថា **ព្រះបាទសម្តេចព្រះរាជឱង្ការជ័យជេដ្ឋាធិរាជរាមាធិបតី** ។ ព្រះរាជបុត្រទី២ **ចៅពញាតន់** ដែលមានព្រះជន្មទើបបាន ៦ វស្សាត្រូវបានតាំងអោយឡើងជាឧបរាជ ។ ឯព្រះ **ស្រីសុរិយោពណ៌** ត្រូវបានឡើងជាឧភយោរាជ ។ ដោយព្រះរាជបុត្រសុទ្ធតែនៅក្មេងៗពេកកិច្ចការគ្រប់គ្រងរដ្ឋស្ថិតនៅក្នុងកណ្តាប់ព្រះហស្តព្រះ **សត្ថា** ទាំងអស់ ។ ត្រង់នេះ មានសំនួរចោទឡើងថា បើព្រះអង្គនៅតែកាន់អំណាចដដែលដូច្នេះ ហេតុអ្វីក៏ចាំដាក់រាជ្យថ្វាយទៅព្រះរាជបុត្រ ? អ្នកប្រវត្តិសាស្ត្រខ្លះបានអោយយោបល់ថា ហេតុដែលនាំអោយព្រះ **សត្ថា** ទ្រង់ប្រព្រឹត្តដូច្នេះ ព្រោះព្រះអង្គខ្លាចក្រែងរាជសម្បត្តិពុំបានទៅព្រះរាជបុត្រតែបានទៅព្រះ **ស្រីសុរិយោពណ៌** វិញនៅពេលដែលព្រះអង្គសោយទិវង្គត ព្រោះអនុជអង្គនេះជាស្តេចមានសមត្ថភាព ហើយត្រូវបានប្រជារាស្ត្រភាគច្រើនគោរពស្រឡាញ់រាប់អានទៀតផង ។

ឯកសារខ្មែរបានបញ្ជាក់ថា អំពើរបស់ព្រះ **សត្ថា** ខាងលើនេះ បានបណ្តាលអោយមានការអាក់អន់ស្រពន់ចិត្តជាច្រើនពីសំណាក់រាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីនិងអាណាប្រជានុរាស្ត្រ ។ ចោរលួច ចោរប្លន់ ក៏កើតឡើងព្រោងព្រាត ។

រីឯប្រជារាស្ត្រខ្មែរកាលបើដឹងថា គ្រាប់ដែលសៀមបាញ់ចូលក្នុងរបងឫស្សីជាប្រាក់សុទ្ធ ក៏មានចិត្តត្រេកអរពន់ពេក នាំគ្នាកាប់ឆ្ការព្រៃឫស្សីដើម្បីយកប្រាក់នោះទោះបីមានបំរាមពីព្រះរាជាយ៉ាងណាក៏ពុំព្រមស្តាប់ ហើយចេះតែនាំគ្នាប្រព្រឹត្តអំពើនោះរហូតដល់ធ្លុះធ្លាយរបងឫស្សីអស់ ។

នៅគ.ស. ១៥៩៣ សៀមបានលើកទ័ពចូលវាយបន្ទាយលង្វែកម្តងទៀត ។ ព្រះ **នរេសូរ** បានបញ្ជាអោយទ័ពចូលជា៣ផ្លូវ ។ ខ្មែរលើកទ័ពចេញទៅតទល់ តែលើកនេះក៏ដូចជាលើកមុនសៀមវាយយកបានជាបន្តបន្ទាប់គ្នានូវ **បន្ទាយពោធិ៍សាត់** និង**បន្ទាយបរិបូណ៌** ។ ព្រះឧភយោរាជ**ស្រីសុរិយោពណ៌** បកសំបុត្រទៅអោយកែនទ័ព ប្រមូលស្បៀងចូលការពារក្នុង **បន្ទាយលង្វែក** ។ ទ័ពដែលចេញទៅទប់ខាង**នគររាជ្យ** ក៏ទប់ពុំជាប់ ។ ឯខាងជើងទឹក ក៏ចាញ់សៀមទៀត ។ សៀមវាយកាន់តែខ្លាំងឡើង ព្រះឧភយោរាជថយមកនៅ **បន្ទាយរលាផ្អៀរ** ហើយសុំជំនួយពីលង្វែក ។ សៀមលើកទ័ពមកព័ទ្ធបន្ទាយទៀត ។ លុះទ័ពសៀមមកជិតដល់ ព្រះ**សត្ថាទី១** នាំបុត្រនាម **ជ័យជេដ្ឋា** និង**ចៅពញាតន់** ភៀសទៅគង់នៅស្រីសន្ធរ ក្រោយមកទៀតភៀសទៅស្ទឹងត្រែង ហើយនៅទីបំផុតភៀសទៅគង់នៅ **វៀងចន្ទន៍** ជារាជធានីប្រទេសលាវ **លានឆាង** ។

ចំណែកឯ **ស្រីសុរិយោពណ៌** បានស្ថិតនៅក្នុងបន្ទាយលង្វែកដើម្បីប្រយុទ្ធនឹងខ្មាំង ។ តែទោះបីព្រះអង្គបានខិតខំការពារបន្ទាយយ៉ាងស្វិតស្វាញយ៉ាងណាក៏ដោយ ក៏បន្ទាយនេះត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃខ្មាំងក្រោយពីត្រូវឡោមព័ទ្ធអស់រយៈពេល ៣ ខែ ព្រោះវាបានយកចំបើងដុតរបងឫស្សីដែលនៅសល់បន្តិចបន្តួចនោះនៅគ. ស. ១៥៩៣ ។ សៀមចាប់បានព្រះឧភយោរាជ **ស្រីសុរិយោពណ៌** និងបុត្រទាំងពីរគឺព្រះ**ជ័យចេស្ដា** (ព្រះជន្ម ១៥ វស្សា) និងព្រះ**ឧទ័យ** (ព្រះជន្ម ៥ វស្សា) នាំយកទៅប្រទេសសៀមព្រមជាមួយនឹងក្បួនខ្នាតអ្នកប្រាជ្ញបណ្ឌិតកវី រូបបដិមា **ព្រះគោព្រះកែវ** និងឈ្លើយខ្មែរជាច្រើនទៀត ។ ក្រោយពីបានស្នាក់នៅក្នុងប្រទេសខ្មែរអស់ ៣ ខែ ព្រះ**នរេសូរ**បានយាងត្រឡប់ទៅក្រុង**អយុធ្យា** វិញ ទុកអោយតែមហាមន្ត្រីសៀមនៅឈរនៅក្រុងឧដុង្គ ។ គួរគប្បីជ្រាបនៅខាងមុខព្រះ **វិហារព្រះកែវ** នៅក្រុងបឹងកកប្រទេសថៃសព្វថ្ងៃ មានរូបបដិមា **ព្រះគោ** ដែលមានទំហំសឹងប៉ុនសត្វគោធំ ពោះប្រហោងក្នុង ។ តើនេះជានិមិត្តរូប **ព្រះគោព្រះកែវ** ដែលសៀមបាននាំយកបានទៅនៅគ្រាដែលវាយបែកបន្ទាយលង្វែក ឬយ៉ាងណា ?

ចំពោះចំបាំងខ្មែរ-សៀមនៅគ. ស. ១៥៩៣នេះ ឯកសារសៀមបាននិយាយថា មកតែពីខ្មែរមិនរក្សាពាក្យសច្ចៈទើបព្រះ **នរេសូរ** លើកទ័ពមកសងសឹក ។ សម្ដេចព្រះ **នរេសូរ** ឃើញកម្លាំងកម្ពុជាទន់ខ្សោយ ទើបមានតម្រាស់អោយព្រះ **សត្ថា** មកគាល់ តែព្រះ **សត្ថា** ត្រឡប់ជាចាប់ទូតថៃ ដែលអញ្ជើញព្រះបរមរាជឱង្ការឃុំទុក ហើយក៏បញ្ជូនទ័ពតស៊ូយ៉ាងខ្លាំង (8) ។ ម្យ៉ាងទៀតរាជពង្សាវតារសៀមបានអះអាងថា ទ័ពសៀមបានចាប់បានទាំងព្រះមហាក្សត្រខ្មែរ ហើយព្រះចៅសៀមទ្រង់បញ្ជាអោយ ប្រហារជីវិតព្រះអង្គ ដើម្បីយកព្រះលោហិតទៅលាងព្រះបាទទៀតផង (9) និង (10) ។ សព្វថ្ងៃនេះ នៅវត្ត **យ៉ៃជ័យមង្គល** នាខេត្ត **អយុធ្យា** គេឃើញមានរូបគំនូរ ២ ផ្ទាំងដែលគួរអោយចាប់អារម្មណ៍ : រូបទី ១ ជារូបស្ដេចខ្មែរគង់អង្គុយលើកៅអី ១ ទាប មានព្រះសុរង្គព្រះបាទ និងព្រះហស្តជាប់ចំណង និងច្រវាក់ រូបទី២ បង្ហាញពីបុរសម្នាក់ស្លៀកពាក់សកំពុងតែលុតជង្គង់យកលោហិតស្ដេចខ្មែរទៅលាងព្រះបាទអោយស្ដេចសៀម ។ តើរឿងនេះជាការពិតឬក៏ជារឿងប្រឌិតសំរាប់តែ លើកសរសើរពីមហិទ្ធិរិទ្ធព្រះចៅសៀមនាសម័យនោះ ? រាជពង្សាវតារខ្មែរគ្រប់ក្បួនទាំងអស់ពុំឃើញមាននិយាយពីព្រឹត្តិការណ៍នេះឡើយ ។

## ១.២. ទំនាក់ទំនងជាមួយអឺរ៉ុប

បើតាមប្រភពអឺរ៉ុប **ព្រះសត្ថា** ជាក្សត្រទន់ខ្សោយហើយទ្រង់មានព្រះហឫទ័យច្រណែនចំពោះព្រះអនុជគឺ **ព្រះស្រីសុរិយោពណ៌** ។ ដោយហេតុថាព្រះអង្គត្រូវការជំនួយដើម្បីប្រឆាំងនឹងសត្រូវ ខាងក្នុង និងខាងក្រៅ ព្រះអង្គក៏ទ្រង់បានយកចិត្តពួកអ្នកផ្សាយសាសនាយ៉ាងខ្លាំង ។ ពួកនេះមានសិទ្ធិពេញ

លេញក្នុងការផ្សាយលទ្ធិរបស់ខ្លួន មានសិទ្ធិសង់ព្រះវិហារនៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រ ។ ព្រះរាជាទ្រង់បានជួយឧបត្ថម្ភពួកនេះរហូតដល់បានបញ្ជូនអង្ករនិងវត្ថុផ្សេងៗ ទៀតទៅអោយអង្គការដូមីនីកាំងនៅ Malacca ។ នៅគ. ស. ១៥៨៥ នាយចៅហ្វាយរបស់បព្វជិត Sylvestre បានសំរេចចិត្តថាត្រូវតែគាំទ្រលោក ហើយបានបញ្ជូនមកជាបន្ថែមនូវបព្វជិតទៀត គឺបព្វជិត Antonio Dorta និងបព្វជិត Antonio Caldeira ។ ក្នុងពេលដំណាលគ្នានោះ មានបព្វជិតខាងគណៈ ហ្វ្រង់ស៊ីស្កាំង (Franciscain) ក៏បានមកប្រទេសខ្មែរដែរ : ក្នុងចំណោមនេះ មានបព្វជិតនាម Gregorio Ruiz ។ តែដោយមានការធ្វើទុក្ខបុកម្នេញកើតឡើងជាថ្មីទៀត បព្វជិតទាំងពីរអង្គខាងក្រោយ នេះក៏និមន្តត្រឡប់ទៅវិញអស់ ។ ពេលនោះបព្វជិត Sylvestre បានប្រើឥទ្ធិពលរបស់លោក ហើយ **ព្រះសត្ថាទី១** ក៏ទ្រង់អនុញ្ញាតនៅគ. ស. ១៥៨៩ ថាបព្វជិតអង្គណាក៏ដោយ អាចផ្សាយសាសនាបាននៅគ្រប់ទីកន្លែងក្នុងប្រទេសខ្មែរ ហើយជនជាតិខ្មែរណាក៏ដោយក៏អាចកាន់សាសនាថ្មីនេះបានដោយគ្មានខ្លាចពីការសងសឹកឡើយ ។ ដោយហេតុនោះ បព្វជិត Sylvestre ក៏បានសុំអោយអង្គការកណ្តាលបញ្ជូនបព្វជិតមកជាបន្ថែម ។ ជាការឆ្លើយតបនឹងសេចក្តីអំពាវនេះ បព្វជិត Jorge de Mota និង Luis de Fonseca ក៏ត្រូវបានគេបញ្ជូនមកទៀត តែនៅពេលនោះលោកទាំងពីរនិមន្តមកដល់ បព្វជិត Sylvestre ក៏បានសុគតរួចទៅហើយ (19) ។

គួរគប្បីជ្រាបថា នៅគ្រានោះមិនគ្រាន់តែមានពួកបព្វជិតទេ ដែលបានមកប្រទេសខ្មែរ ពួកអ្នកផ្សងព្រេងខ្លះក៏បានមកក្នុងពេលជាមួយគ្នាដែរ ។ នៅគ. ស. ១៥៨៥ ជនជាតិព័រទុយក័ល ដែលមានវ័យនៅក្មេង (២០ឆ្នាំ)ឈ្មោះ Diogo Veloso បានមកដល់ប្រទេសខ្មែរជាមួយបក្សពួកមួយក្រុមគឺ Carneiro, Machado, Sagredo, Diogo de chaves Carnizares ។ល។ ប៉ុន្មានឆ្នាំក្រោយមកទៀត(ដើមគ. ស. ១៥៩៣) អ្នកផ្សងព្រេងជាតិអេស្ប៉ាញក៏បានមកដល់ គឺលោក Ruiz de Hernan Gonzalès និង Vargas Machuca ។

ពួកជនផ្សងព្រេងទាំងនេះត្រូវបាន**ព្រះសត្ថា** ស្រឡាញ់រាប់អានយ៉ាងខ្លាំងហើយពួកនេះក៏ជាប់ជំពាក់ចិត្តយ៉ាងខ្លាំងជាមួយនឹងព្រះអង្គវិញដែរ ។ ព្រះ**សត្ថា** ទ្រង់សព្វព្រះទ័យរៀបអភិសេកប្អូនជីដូនមួយស្រីម្នាក់របស់ព្រះអង្គអោយទៅលោក Diogo Veloso ឯចំណែកលោក Ruiz ត្រូវបានព្រះអង្គតែងតាំងជាអង្គរក្សរបស់ព្រះអង្គ (9) ។

រួចមកហើយ យើងឃើញថានៅគ. ស. ១៥៩៣ ព្រះចៅសៀមនាមព្រះ **នរេសូរ** បានលើកទ័ពចូលមកវាយខ្មែរជាលើកទី២ ដោយមានរេហ៍ពលច្រើនជាងលើកទី១ទៅទៀត ។ តាមរយៈ Veloso ព្រះ **សត្ថាទី ១** ទ្រង់បានទាក់ទងជាមួយអ្នកកាន់អំណាចព័រទុយក័លនៅ Malacca តែពួកព័រទុយក័លមិនអាចជួយខ្មែរ ព្រោះរវល់តែជាប់ដៃច្បាំងនឹងពួកម៉ាឡាយូនៅ Acheh និងនៅ Johore (20) ។ ដោយហេតុនោះ ព្រះ **សត្ថាទី១** ទ្រង់ងាកទៅរកជំនួយពីពួកអេស្ប៉ាញវិញតាមការថ្វាយយោបល់របស់លោក Ruiz និង Vargas ។

គួរគប្បីជ្រាបថាជនជាតិអេស្ប៉ាញជាជនជាតិអឺរ៉ុបដែលបានមកកាន់អាស៊ីអាគ្នេយ៍បន្ទាប់ពីពួកព័រទុយក័ល ។ ពួកនេះបានវាយប្រទេសហ្វីលីពីនដាក់ជាអាណានិគមរបស់ខ្លួនក្នុងរាជ្យស្ដេច Philippe ទី២ ហើយការវាយប្រទេសហ្វីលីពីននេះ ជាស្នាដៃរបស់មេទ័ពជើងទឹកម្នាក់ឈ្មោះ Miguel Lopez de Legaspi ។ ពួកអេស្ប៉ាញបានត្រួតត្រាប្រទេសហ្វីលីពីន ពីគ. ស. ១៥២៧ ដល់ គ. ស. ១៨៩៦ ហើយបានតាំងរាជធានីរបស់ខ្លួននៅក្រុងម៉ានីល ។

នៅខែ កក្កដា ១៥៩៣ ព្រះ**សត្ថាទី ១** ទ្រង់ចាត់អោយលោក Veloso មួយអន្លើនឹង Vargas និង Carneiro នាំយកព្រះរាជសារទៅជូនលោកទេសាភិបាលអេស្ប៉ាញនៅក្រុងម៉ានីលដើម្បីសុំជំនួយទ័ពមកច្បាំងនឹងសៀម ។ ដើម្បីជាសគុណ ព្រះអង្គទ្រង់បានសន្យាថានឹងបើកសិទ្ធិអោយពួកអេស្ប៉ាញ មកផ្សាយសាសនា និងធ្វើជំនួញនៅប្រទេសខ្មែរ ។ លោកទេសាភិបាលអេស្ប៉ាញឈ្មោះ Gomez Perez Dasmarinas បានសរសេរលិខិតចុះថ្ងៃ២៧ ខែកញ្ញា ១៥៩៣ ឆ្លើយតបមកព្រះរាជាខ្មែរវិញ ថានឹងជួយផ្សះផ្សាជម្លោះរវាងខ្មែរ និងសៀម ។ លោកពុំបានបញ្ជូនជំនួយទ័ពមកជួយខ្មែរទេ ព្រោះលោកកំពុងតែរៀបចំទៅវាយយកកោះម៉ូលុក (Moluques) ។ ជាអកុសល នៅពេលដែលចេញដំណើរនៅថ្ងៃ៣០ ខែកញ្ញា ១៥៩៣ លោកត្រូវពួកចិនអ្នកអុំសំពៅលោកលួចធ្វើឃាតលោកទៅ (9) ។

កូនប្រុសលោកឈ្មោះ Luis Perez Dasmarinas បានឡើងកាន់អំណាចជំនួសឪពុកលោក ។ លោកទេសាភិបាលថ្មីនេះបានសរសេរលិខិតមួយទៀតផ្ញើទៅថ្វាយព្រះរាជាខ្មែរ ។ Veloso និងបក្សពួកបានសំបុត្រនោះហើយក៏ធ្វើដំណើរត្រឡប់មកប្រទេសខ្មែរវិញ ។ តែជាអកុសល ទ័ពសៀមបានវាយលុកយកបានបន្ទាយលង្វែកជាស្រេច ។

Veloso និង Carneiro បានធ្វើសង្គ្រាមវាយឆ្មក់ប្រឆាំងនឹងពួកសៀមតែត្រូវចាប់បានហើយយកទៅឃុំឃាំងជាមួយនឹង Ruiz ជាអ្នកនៅការពារបន្ទាយលង្វែកជាមួយនឹងព្រះឧភយោរាជ**ស្រីសុរិយោពណ៌** ។ ក្រៅពីនេះ មានបព្វជិតជាតិអឺរ៉ុបខ្លះទៀតត្រូវសៀមចាប់យកទៅក្រុងអយុធ្យាដែរ គឺបព្វជិត Jorge de Mota និង Luis de Fonseca ។

ពួកឈ្លើយសង្គ្រាមទាំងនោះ ខ្លះត្រូវបានដឹកនាំទៅតាមផ្លូវគោក ខ្លះទៀតទៅតាមផ្លូវទឹក ។ លោក Ruiz, Carneiro និង Machado ត្រូវគេដឹកទៅតាមសំពៅមួយ ។ លោក Ruiz បាននាំពួកឈ្លើយបះបោរឡើង ដណ្ដើមយកបានសំពៅ ហើយធ្វើដំណើរឆ្ពោះទៅក្រុងម៉ានីល (ទៅដល់នៅខែ មិថុនា ១៥៩៤) ។

ចំណែកឯលោក Veloso នៅក្រុង **អយុធ្យា** ត្រូវបានព្រះ **នរេសូរ** ចាត់អោយនាំរាជទូតសៀមទៅក្រុងម៉ានីលដើម្បីសុំចងសម្ព័ន្ធមេត្រីជាមួយពួកអេស្ប៉ាញនៅគ. ស. ១៥៩៥ ។ លុះសំពៅមកដល់ច្រក

ទន្លេមេណាម គេក៏បានដំណឹងតាមទាហានសៀមដែលបាក់ទ័ពពីលង្វែកថាស្តេចខ្មែរដណ្តើមអំណាចបានវិញហើយ ។ លោក Veloso មិនដឹងថាព្រះ **រាមជើងព្រៃ** ស្មានថា **ព្រះសត្ថា** ។ លោកក៏បន្តដំណើរទៅដល់ក្រុងម៉ានីលនៅពាក់កណ្តាលខែ មិថុនា ១៥៩៥ ហើយបានជួបនឹងមិត្តរបស់លោកគឺ Ruiz, Carneiro និង Machado ។ ដូច្នេះ ត្រង់ដែលត្រូវការពារផលប្រយោជន៍របស់សៀម លោក Veloso បែរជាមានគំនិតគិតត្រឡប់មកជួយខ្មែរវិញ ។ ដោយហេតុនោះ លោកបានស្រុះស្រួលជាមួយមិត្តភក្តិលោកធ្វើអន្តរាគមន៍សុំជំនួយពីពួកអេស្ប៉ាញ ដើម្បីមកជួយព្រះរាជាខ្មែរ ហើយបានទទួលការគាំទ្រយ៉ាងសកម្មជាពិសេសពីសំណាក់លោកទេសាភិបាល Luis Perez Dasmarinas ។

## ២. ផលវិបាកនៃការបែកបាក់ក្រុងលង្វែក

ការវាយបែកក្រុងលង្វែកដោយជនជាតិសៀមមានផលវិបាកអាក្រក់យ៉ាងខ្លាំងសំរាប់ប្រជាជាតិខ្មែរ ។ តពីនេះទៅទៀតខ្មែរត្រូវពើបប្រទះនឹងវិបត្តិកាន់តែច្រើនឡើង ។ យ៉ាងណាមិញ ទំនាស់ផ្ទៃក្នុងបូករួមជាមួយនឹងកត្តាផ្សេងៗដទៃទៀត បានញ៉ាំងមហាអំណាចខ្មែរអង្គរអោយចុះទន់ខ្សោយ បន្តិចម្តងៗរហូតដល់លើករាជធានីពី **យសោធរបុរ** មកតាំងនៅទួលបាសាន រួចនៅចតុមុខ ។ នៅសម័យលង្វែក ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទ **ចន្ទរាជា** និង **បរមរាជាទី ៤** ខ្មែរបានពង្រឹងជំហររបស់ខ្លួនបានវិញ ហើយមានលទ្ធភាពលើកទ័ពទៅវាយលុករាជធានីស្រីអយុធ្យា និងវាយរំដោះយកអាណាខេត្តខាងលិចមកវិញបានជាច្រើន ។ ប៉ុន្តែ ក្រោយពីបន្ទាយលង្វែកត្រូវបែកបាក់ទៅ ទឹកដីមួយភាគធំនៅឯនាយភ្នំដងរែក និងនៅខាងលិចត្រូវបាត់បង់ទៅវិញជាស្ថាពរ ។

ការបែកបាក់បន្ទាយលង្វែកជាហេតុញ៉ាំងប្រទេសខ្មែរអោយអស់ឫទ្ធានុភាព ធ្លាក់ខ្លួនជារដ្ឋតូចតាចនៅភូមិភាគអាស៊ីអាគ្នេយ៍ ។ នេះជាលើកទី៣ ហើយដែលខ្មែរត្រូវបាត់បង់អស់ក្បួនខ្នាត អ្នកប្រាជ្ញបណ្ឌិតកវីដែលត្រូវខ្មាំងកៀរយកទៅស្រុកវា ។ ម្យ៉ាងទៀតអនាធិបតេយ្យក៏កើតមានឡើងហើយនៅចុងសតវត្សទី ១៦នេះ គេឃើញមានការជ្រែករាជ្យរហូតដល់ទៅពីរលើក ។

### ២.១. ការជ្រែករាជ្យនៃព្រះរាមជើងព្រៃ (១៥៩៤ - ១៥៩៦)

ព្រះ **រាមជើងព្រៃ** ត្រូវជាព្រះញាតិរបស់ព្រះ**សត្ថាទី ១** ។ នៅគ.ស.១៥៩៤ ព្រះអង្គបានលើកទៅវាយសៀមនៅបន្ទាយឧដុង្គ ។ សៀមចាញ់ក៏ដកថយទៅស្រុកវិញអស់ទៅ ។ ព្រះ**រាមជើងព្រៃ** (តាមឯកសារព័រទុយក័ល ហៅថា Anacaparan) បានឡើងសោយរាជ្យនៅស្រីសន្ធរ (Siri Strol ឬ Sistor) ។

រួចមកហើយ យើងបានឃើញថាលោក Veloso កាលដែលទៅសុំជំនួយពីទេសាភិបាលអេស្ប៉ាញ នៅប្រទេសហ្វីលីពីនបំរុងយកមកជួយព្រះ**សត្ថាទី ១** នោះ ឃើញថាបានទទួលការគាំទ្រយ៉ាងសកម្ម ជាពិសេសពីសំណាក់លោកទេសាភិបាល Luis Perez Dasmarinas តែម្តង ។

បើតាមឯកសារអឺរ៉ុប លោក Veloso បានធ្វើបញ្ជីនៃតម្រូវការហើយដាក់ជូនទៅលោកទេសាភិបាល ។ ក្នុងបញ្ជីនោះមានគ្រោងពីការតាំងអាណាព្យាបាលភាពរបស់អេស្ប៉ាញមកលើប្រទេសខ្មែរ និងការផ្លាស់សាសនារបស់ប្រជារាស្ត្រខ្មែរទាំងស្រុង (19) ។ កងនាវាបានចេញដំណើរពីក្រុងម៉ានីលនៅថ្ងៃទី១៩ មករា ១៥៩៦ ហើយត្រូវស្ថិតនៅក្រោមបញ្ជាការរបស់មេទ័ពឈ្មោះ Jaurez Gallinato: ពលទាហានមានប្រមាណពី ១២០ ទៅ ១៣០នាក់ ជនជាតិជប៉ុនកាន់សាសនាគ្រិស្ត ២០នាក់ ជនជាតិហ្វីលីពីនខ្លះ និងបព្វជិតគណៈដូមីនីកាំង ៣អង្គ ។ មេពួកបព្វជិតគណៈដូមីនីកាំង គឺបព្វជិត Alonso Jimenez ជាសហមេបញ្ជាការនៃប្រតិបត្តិការនេះ (19) ។

លុះធ្វើដំណើរមកដល់ក្រុងចតុមុខ (churdumuco) លោក Ruiz និងលោក Veloso ទើបភ្ញាក់ខ្លួនដឹងថាព្រះ**សត្ថាទី ១** (Apran Langara) និងរាជបុត្រ ២អង្គបានភៀសទៅប្រទេសលាវហើយ ហើយមានក្សត្រថ្មីឡើងសោយរាជ្យរួចស្រេចដែរ ។ នៅថ្ងៃទី ១២ មេសា ១៥៩៦ ជម្លោះមួយបានផ្ទុះឡើងរវាងពួកឈ្មួញចិន និងពួកទាហានជើងទឹកអេស្ប៉ាញ ។ ឈ្មួញចិនប្រមាណ ១០០នាក់ត្រូវស្លាប់ ហើយទំនិញនិងសំពៅរបស់ខ្លួនក៏ត្រូវរឹបអូសទាំងអស់ ។ លោក Veloso បានសុំអនុញ្ញាតពីព្រះ **រាមជើងព្រៃ** អោយចូលគាល់ដើម្បីបំភ្លឺព្រះអង្គពីឧប្បត្តិហេតុដែលបានកើតឡើងនោះ តែព្រះរាជាដាក់លក្ខខណ្ឌថាទាល់តែពួកអេស្ប៉ាញព្រមសងទំនិញទៅពួកចិនទាំងអស់ជាមុនសិន ទើបព្រះអង្គទ្រង់អនុញ្ញាតអោយបាន (9) ។ ដោយហេតុនោះលោក Veloso និងលោក Ruiz បានសំរេចថាត្រូវតែប្រើកម្លាំងទ័ពវិញ : ជាមួយនឹងទាហាន ៣៨ នាក់គេបាននាំគ្នាទៅឡោមព័ទ្ធវាំងនៅស្រីសន្ធរនៅពេលយប់ ធ្វើគត់ព្រះ **រាមជើងព្រៃ** បានមុនពេលថ្ងៃរះ (ឯកសារខ្លះថានៅម៉ោង ២ល្ងាច) រួចវិលត្រឡប់មកក្រុងភ្នំពេញ ហើយបានជួបនឹងកងនាវារបស់លោក Callinato ដែលត្រូវខ្យល់បក់រុញច្រានរហូតទៅដល់សិង្ហបុរីនឹងត្រូវសំចតនៅ Malacca ដើម្បីធ្វើការជួសជុលខ្លះ ។ លោក Callinato មានសេចក្តីមិនពេញចិត្តចំពោះសកម្មភាពរបស់ទាហានលោក ។ លោកបានបង្ខំអោយទាហានសងទំនិញដែលបានប្លន់យកពីពួកឈ្មួញចិន ហើយក្រោយពីបានធ្វើការពិនិត្យអោយស្គាល់ទឹកដីបន្តិចបន្តួច ក៏បានចេញដំណើរឆ្ពោះទៅប្រទេសចាម្ប៉ា ទោះបីមានការប្រឆាំងតវ៉ាពីសំណាក់លោក Veloso និងពួកបព្វជិតយ៉ាងណាក៏ដោយ ។ លោកបានចូលសំចតនៅ Cachan (Faifo) ដើម្បីអោយលោក Ruiz និងលោក Veloso ធ្វើដំណើរទៅវៀងចន្ទន៍នាំយកពត៌មានទៅថ្វាយព្រះ **សត្ថាទី១** ស្តីពីហេតុការណ៍នៅក្នុងប្រទេសខ្មែរ ។ ក្រុមនាវិករបស់លោក Gallinato មានជម្លោះជាមួយឈ្មួញជប៉ុន និងជនជាតិយួននៅលើឆ្នេរសមុទ្រ ហើយដោយខ្លាចរដូវភ្លៀងមកដល់លោកក៏ចេញដំណើរឆ្ពោះទៅក្រុងម៉ានីលវិញនៅដំណាច់គ.ស.១៥៩៦ ។

## ២.២. ព្រះបរមរាជាទី ៦ ចៅពញាតន់ (១៥៨៦-១៥៩៩)

លុះទៅដល់ក្រុងវៀងចន្ទន៍ដោយបានឆ្លងកាត់តាមជួរភ្នំអាណ្ណាមមក លោក Ruiz និង Veloso មានសេចក្ដីសោកស្ដាយយ៉ាងខ្លាំងដោយដឹងថា **ព្រះសត្ថាទី១** និងព្រះរាជបុត្រច្បងគឺ **ជ័យជេដ្ឋា** បានសោយទិវង្គតរួចទៅហើយ ។ លោកទាំងពីរក៏បានដង្ហែព្រះរាជបុត្របន្ទាប់គឺ **ចៅពញាតន់** រាជវង្សានុវង្ស និងទាហានលាវខ្លះអោយត្រឡប់ចូលមកប្រទេសខ្មែរវិញ ។ នៅតាមផ្លូវ គេបានជួបប្រទះនឹងកងទ័ពជើងទឹកមួយដែលស្ថិតក្រោមបញ្ជាការរបស់ជ្វាម្នាក់ ដែលព្រះ **រាមជើងព្រៃ**បានតាំងអោយធ្វើជាមេទ័ព ។ មេទ័ពជ្វារូបនេះបានគាំទ្រ និងការពារបុត្រមួយអង្គរបស់ព្រះ **រាមជើងព្រៃ** ប៉ុន្តែនៅពេលដែលពួកនាម៉ឺនសព្វមុខមន្ត្រីបានទទួលស្គាល់ **ចៅពញាតន់** ជាក្សត្រមានសិទ្ធិឡើងសោយរាជ្យ គាត់ក៏យល់ស្របតាមគេដែរ ។

ដូច្នេះ **ចៅពញាតន់** ក៏បានឡើងសោយរាជសម្បត្តិនៅរាជធានីស្រីសន្ធរ ដោយមានព្រះនាមសំរាប់រាជ្យថាព្រះ **បរមរាជាទី ៦** ហើយឯកសារអឺរ៉ុបហៅថា Prauncar ។ គួរកត់សំគាល់ថា គ្រានោះបុត្ររបស់ព្រះ **រាមជើងព្រៃ** ត្រូវបានពួកជ្វា ចិន និងជប៉ុនខ្លះគាំទ្រយ៉ាងសកម្ម ចំណែកឯព្រះ**បរមរាជា**មានតែពួកព័រទុយក័ល អេស្ប៉ាញ និងជប៉ុនភាគច្រើនគាំទ្រប៉ុណ្ណោះ ។

តាមឯកសារអឺរ៉ុបថា មេទ័ពជ្វាដែលមានងារជា **លក្ស្មណា** (ឯកសារខ្មែរថាជាឈ្មោះទៅវិញ) មានការច្រណែននិន្ទានឹងជនជាតិអឺរ៉ុប ហើយពុំបានបំពេញកិច្ចការរដ្ឋអោយបានដិតដល់ទេ ។ ចំណែកឯពួកទាហានលាវដែលបានដង្ហែ **ចៅពញាតន់** ត្រឡប់ចូលស្រុកវិញនោះបានបះបោរ ហើយនៅទីបំផុតក៏ត្រឡប់ទៅវិញអស់ទៅ ។ ដើម្បីជាសគុណ ព្រះ**បរមរាជាទី ៦** បានតែងតាំងលោក Veloso ជាចៅហ្វាយស្រុកខេត្តបាណាម ឯលោក Ruiz ជាចៅហ្វាយស្រុកខេត្តទ្រាំង ក៏ដូចជាព្រះបិតារបស់ព្រះអង្គដែរ ព្រះ**បរមរាជាទី ៦**ទ្រង់បានផ្ញើសារទៅក្រុងម៉ានីលដើម្បីសុំអោយពួកបព្វជិតនិមន្តមកប្រទេសខ្មែរ ដោយទ្រង់សន្យាថានឹងជួយសង់ព្រះវិហារ និងទ្រង់អនុញ្ញាតអោយជនជាតិខ្មែរចូលសាសនាគ្រិស្តទៅតាមជំនឿរបស់ខ្លួន ។ បន្ទាប់ពីនោះ គេឃើញមានបព្វជិតខ្លះបានមកដល់ប្រទេសខ្មែរខ្លះដោយចេតនាខ្លះដោយចៃដន្យ ។ ប៉ុន្តែស្ថានភាពរបស់ជនជាតិអឺរ៉ុបពុំបាននឹងន ។ គេថាព្រះ **បរមរាជាទី ៦** ជាមនុស្សខិលខូចជាងព្រះបិតាព្រះអង្គទៅទៀត ហើយត្រូវដឹកនាំដោយពួកមហេសី និងព្រះមាតាក្មេកដែលក្លាយជាសហាយរបស់មេទ័ពជ្វាឈ្មោះ **លក្ស្មណា** ។ បើតាមលោក Ruiz ថានៅពាក់កណ្ដាលគ.ស.១៥៩៨ ទៅហើយព្រះរាជាពុំទាន់បានទទួលរាជាភិសេកសោយរាជសម្បត្តិនៅឡើយ ឯលោក Ruiz និងលោក Veloso ក៏ពុំទាន់បានទៅកាន់អំណាចក្នុងខេត្តរបស់ខ្លួនដែរ ។

ដើម្បីពង្រឹងអំណាចរបស់ព្រះអង្គ ហើយដោយមានសំណើពីលោក Ruiz ផង ព្រះរាជាទ្រង់បានផ្ញើសារទៅជូនលោកទេសាភិបាលថ្មីនៃប្រទេសហ្វីលីពីន ដើម្បីសុំជំនួយជាទ័ពនិងអ្នកផ្សាយសាសនា ។

កាលណោះ មានការជំទាស់យ៉ាងខ្លាំងចំពោះការសុំជំនួយនេះ ប៉ុន្តែលោក Luis Perez Dasmarinas ទទួលរៀបចំប្រតិបត្តិការមួយដោយចេញសោហ៊ុយផ្ទាល់របស់លោក ។ នៅថ្ងៃ ១៧ ខែកញ្ញា ១៥៩៨ កប៉ាល់នាវាមួយដឹកនាំទាហានអេស្ប៉ាញ ២០០នាក់ បព្វជិតដូមីនីកាំង ២អង្គ បព្វជិតហ្វ្រង់ស៊ីស្កាំង២អង្គបានចេញដំណើរពីក្រុងម៉ានីលឆ្ពោះមកប្រទេសខ្មែរ ក្រោមបញ្ជាការរបស់លោក Luis Perez Dasmarinas ប៉ុន្តែជាអកុសល កប៉ាល់នាវាត្រូវជួបប្រទះនឹងខ្យល់ព្យុះបក់ទៅទើរនៅប្រទេសចិនជិតក្រុងកង់តុង ។ ជនដែលរស់រានមានជីវិតទាំងប៉ុន្មានបានត្រឡប់ទៅក្រុងម៉ានីលវិញ ។ កប៉ាល់មួយដែលបានទទួលបេសកកម្មអោយស្វែងរកពួកជនរងគ្រោះហើយដែលបានដឹកនាំទាហាននិងបព្វជិតបានមកដល់ចតុមុខនៅ គ.ស. ១៥៩៩ ។ ជម្លោះមួយបានកើតឡើងរវាងពួកនាវិកអេស្ប៉ាញ និងពួកជ្វា ។ លុះដឹងដំណឹងនេះលោក Veloso និងលោក Ruiz បានមកដល់កន្លែងកើតហេតុ ហើយត្រូវគេសម្លាប់ទាំងពីរនាក់ ។ ព្រះរាជាលើកទ័ពមកដោយផ្ទាល់ព្រះអង្គ ហើយត្រូវធ្វើគុតនៅលើសមរភូមិដោយពួកចាមជ្វារបះបោរទៀត (9) ។ គួរគប្បីជ្រាបថា ចំពោះការសោយទិវង្គតរបស់ព្រះបាទ **បរមរាជាទី ៦** នេះ ឯកសារខ្មែរបានផ្តល់ពត៌មានប្លែកពីពត៌មានរបស់ពួកអឺរ៉ុបទៅវិញ ។ យ៉ាងណាមិញ រាជពង្សាវតារខ្មែរខ្លះបាននិយាយថា កាលព្រះអង្គមានព្រះជន្មបាន ២១វស្សា ស្តេចព្រះរាជដំណើរលើកទ័ពចេញទៅចាប់ស្រុកត្បូងឃ្មុំនោះមានចាមឈ្មោះ **ប៉ោរ៉ាត** ១ ជ្វាឈ្មោះ **លក្សិណា** ១ វាលុកស្តេចក្ស័យព្រះជន្មទៅ ។

## ២.៣. ព្រះបរមរាជាទី ៧ ចៅពញាអន (១៥៩៩-១៦០០)

**ចៅពញាអន** ជារាជបុត្រពៅរបស់ព្រះ**សត្ថា** ត្រូវបានពួកនាម៉ឺនសព្វមុខមន្ត្រីយាងអោយឡើងសោយរាជ្យនៅស្រីសន្ធរ ដោយមានព្រះនាមថា **ព្រះបរមរាជាទី ៧** ។ ព្រះអង្គទ្រង់បានបន្តនយោបាយរបស់ដូនតាព្រះអង្គដោយអំពាវនាវអោយពួកអ្នកផ្សាយសាសនាគ្រិស្តចូលក្នុងប្រទេសព្រះអង្គ និងអោយពួកទាហានមកជួយការពារផងដែរ ។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថា ស្តេចអង្គនេះជាក្សត្រមិនប្រកបដោយទសពិធរាជធម៌ ។ ថ្ងៃមួយយាងទៅប្រពាតព្រៃ លុះទៅដល់ភូមិតាមាក់ ទ្រង់សព្វព្រះរាជហឫទ័យស្រឡាញ់ស្ត្រីម្នាក់ជាប្រពន្ធរបស់មេស្រុកឈ្មោះពញាចី ។ ព្រះអង្គទ្រង់បញ្ជាអោយចាប់យកដោយបង្ខំ ហើយដោយស្ត្រីនោះប្រកែកមិនព្រមជិតក្បត់នឹងប្តីរបស់នាង នាងក៏ត្រូវទទួលទារុណកម្មរហូតដល់បាត់បង់ជីវិត ។ ប្តីរបស់នាងមានសេចក្តីក្តៅក្រហាយខ្លាំងចំពោះអំពើរំលោភជិះជាន់បែបនេះក៏រត់ទៅចូលខាង **កែវព្រះភ្លើង** ។ ក្នុងឱកាសបុណ្យចំរើនព្រះជន្មព្រះ **បរមរាជាទី ៧ កែវព្រះភ្លើង** បាននាំបក្សពួកបន្លំចូលធ្វើគុតព្រះអង្គបាននៅរាជវាំងស្រីសន្ធរនៅ គ.ស. ១៦០០ ។

## ២.៤. សម្តេចព្រះកែវហ្វ៊ា ចៅពញាញោម (១៦០០-១៦០៣)

ចៅពញាញោម (ឯកសារអឺរ៉ុបហៅថា Nacque Sumaday Peraorachyoncar) ជាបុត្រពៅព្រះ **សត្ថាទី ១** ។ រាជពង្សាវតារខ្មែរថា ព្រះអង្គបានឡើងគ្រងរាជសម្បត្តិស្នងព្រះបិតុច្ឆានៅពេលដែលព្រះអង្គមានព្រះជន្មាយុ២១ព្រះវស្សា ។ ព្រះអង្គមានព្រះនាមសំរាប់រាជ្យថា **សម្តេចព្រះកែវហ្វ៊ា** គង់នៅព្រះរាជវាំងស្រីសន្ធរ ។

ឯកសារអឺរ៉ុបនិយាយថា ព្រះអង្គទ្រង់បានប្រយុទ្ធប្រឆាំងនឹងព្រះបិតុច្ឆាព្រះនាម **ស្រីសុរិយោពណ៌** ដើម្បីបានឡើងសោយរាជ្យ ។ ព្រះអង្គទ្រង់បានលើករាជធានីមកតាំងនៅភ្នំពេញវិញ (គ.ស.១៦០១) ។ ព្រះអង្គបានបន្តនយោបាយរបស់ក្សត្រសោយរាជ្យមុនៗព្រះអង្គ គឺទ្រង់បានទាក់ទងជាមួយអង្គការផ្សាយសាសនានៅ Malacca ។ នៅដើមគ.ស.១៦០៣ ទេសាភិបាលអេស្ប៉ាញនៅម៉ានីលបានបញ្ជូនទាហាន និងបព្វជិតខ្លះមកប្រទេសខ្មែរជាកិច្ចឆ្លើយតបចំពោះសេចក្តីអំពាវនាវរបស់ **ចៅពញាញោម** ។ ពេលនោះប្រទេសកំពុងតែមានចលាចល ប៉ុន្តែ **ព្រះកែវហ្វ៊ា** ទ្រង់បានទទួលជនបរទេសទាំងនោះយ៉ាងរាក់ទាក់ណាស់ ។ ព្រះអង្គទ្រង់បានជួយកសាងព្រះវិហារ ទ្រង់បានផ្តល់ស្បៀងជាអង្ករ ផ្តល់នូវសេរីភាពផ្សាយសាសនា និងការផ្លាស់សាសនាទៀត ។

ឯកសារអឺរ៉ុបបាននិយាយបន្ថែមទៀតថា នៅគ.ស.១៦០៣ដដែល**ព្រះស្រីសុរិយោពណ៌** ដោយមានជំនួយទ័ពសៀមផង បានលើកមកវាយឈ្នះ**ព្រះកែវហ្វ៊ា** ហើយស្រុកទេសក៏បានសុខសន្តិភាពចាប់តាំងពីពេលនោះមក ។ ស្តេច **ខ្មៅ**(ព្រះនរេសូរ) បាននាំពួកអ្នកផ្សាយសាសនាជាឈ្លើយយកទៅប្រទេសសៀម ។ ប្រភពដដែលនេះបានបញ្ជាក់ទៀតថា : ដោយទ្រង់ទទួលឥទ្ធិពលខ្លាំងពីសៀម **ព្រះស្រីសុរិយោពណ៌** ទ្រង់មិននិយមរាប់អានសាសនាគ្រិស្តទេ ហើយទ្រង់បានបញ្ចូលទំនៀមទំលាប់សៀមមកក្នុងប្រទេសខ្មែរថែមទៀតផង ។

ចំណែកឯរាជពង្សាវតារខ្មែរបាននិយាយថា **ព្រះកែវហ្វ៊ា** ជាក្សត្រមិនរវល់នឹងកិច្ចការផែនដី ចូលចិត្តបណ្តើរគ្នែ គង់សេះដេញសត្វ ចៀតចៀនកូនប្រពន្ធអ្នកដទៃ ជាហេតុបណ្តាលអោយនាម៉ឺនជិះជាន់រាស្ត្រ កើតចោរលួចចោរប្លន់ ទើប**សម្តេចព្រះទេវីក្សត្រី** ត្រូវជាសម្តេចព្រះអយ្យិកាជំនុំនឹងមន្ត្រីរួចផ្ញើសារទៅក្រុងស្រីអយុធ្យា ក្រាបទូលព្រះចៅសៀមបើកសម្តេចព្រះ **ស្រីសុរិយោពណ៌** អោយចេញមកក្រុងកម្ពុជាធិបតី ។

# បញ្ជីស្តេចខ្មែរសោយរាជ្យពីគ.ស. ១៣៩៣ ដល់ ១៦០៣

| លេខ<br>រជ្ជកាល | នាមសំរាប់រាជ្យ<br>នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១ | បរមរាជាទី ២<br>ចៅពញាយ៉ាត | ១៣៩៣-១៤៦៣ | យសោធរបុរ<br>ទួលបាសាន<br>ភ្នំពេញ | បុត្រព្រះបាទសុរិយោវង្ស |
| ២ | នារាយណ៍រាជាទី ១ | ១៤៦៣-១៤៦៩ | ភ្នំពេញ | បុត្រស្តេច ១ |
| ៣ | ស្រីរាជា | ១៤៦៩-១៤៨៥ | ភ្នំពេញ | បុត្រស្តេច ១ |
| ៤ | ស្រីសុរិយោទ័យ | ១៤៧៥-១៤៨៥ | ទួលបាសាន | បុត្រស្តេច ២ |
| ៥ | ស្រីធម្មរាជាទី ១ | ១៤៨៦-១៥០៤ | ភ្នំពេញ | បុត្រស្តេច ១ |
| ៦ | ស្រីសុគន្ធបទ<br>ចៅពញាដាំខាត់រាជា | ១៥០៤-១៥១២ | ទួលបាសាន | បុត្រស្តេច ៥ |
| ៧ | ស្រីជេដ្ឋាធិរាជ<br>ស្តេចកន | ១៥១២-១៥២៥ | ទួលបាសាន<br>ចន្លក់ដូនតី<br>ស្រឡប់ពិជ័យ | ជ្រែករាជ្យ |
| ៨ | បរមរាជាទី ៣<br>ចៅពញាចន្ទរាជា | ១៥១៦-១៥៦៦ | ពោធិ៍សាត់<br>លង្វែក | បុត្រស្តេច ៥ |
| ៩ | បរមរាជាទី ៤<br>(បរមន្ទរាជា) | ១៥៦៦-១៥៧៦ | លង្វែក | បុត្រស្តេច ៨ |
| ១០ | បរមរាជាទី ៥<br>សត្ថាទី ១ | ១៥៧៦-១៥៩៥ | លង្វែក | បុត្រស្តេច ៩ |

| លេខ<br>រជ្ជកាល | នាមសំរាប់រាជ្យ<br>នាមផ្ទាល់ | កាលកំណត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១១ | ជ័យជេដ្ឋាទី ១ | ១៥៨៦-១៥៩៥ | លង្វែក | បុត្រស្ដេច ១០ |
| ១២ | ព្រះរាមជើងព្រៃ | ១៥៩៤-១៥៩៦ | ទួលបាសាន | ជ្រែករាជ្យ |
| ១៣ | បរមរាជាទី ៦<br>ចៅពញាតន់ | ១៥៨៦-១៥៩៩ | ទួលបាសាន | បុត្រស្ដេច ១០ |
| ១៤ | បរមរាជាទី ៧<br>ចៅពញាអន | ១៥៩៩-១៦០០ | ទួលបាសាន | បុត្រស្ដេច ៩ |
| ១៥ | កែវហ្វាទី ១<br>ចៅពញាញោម | ១៦០០-១៦០៣ | ទួលបាសាន<br>ភ្នំពេញ | បុត្រស្ដេច ១០<br>(ជ្រែករាជ្យ)? |

# បញ្ជីឯកសារពិគ្រោះ

1. Henri Marchal, Angkor, Paris, 1955

2. Revue France-Asie, nº spécial pour la civilisation khmère, Saigon, 1955

3. ឯកសារមហាបុរសខ្មែរលេខ៤ បោះពុម្ពផ្សាយដោយលោកអេងសុតនៅភ្នំពេញគ. ស. ១៩៦៩

4. លោកកងគីរី-លោកសែមសូរ : ប្រជុំអនុពាក្យទំនើប ទំព័រ ៨៤ -កំពង់ចាម-១៩៦៣ ។

5. សម្តេចព្រះមហាសុមេធាធិបតី ជួនណាត-ប្រវត្តិនៃវត្តឧណ្ណាលោម-ភ្នំពេញ គ. ស. ១៩៥៣ ។

6. លោកស៊ឹមវ៉ា និងលោកលីអេង - ប្រវត្តិនៃប្រទេសកម្ពុជា (សាកល្បង) បោះពុម្ពហើយ តែមិនបានផ្សាយនៅភ្នំពេញ គ. ស. ១៩៦៩ ។

7. Etienne Aymonier, Le Cambodge , tome III, Paris, 1904.

8. បែបរៀនសង្គមសិក្សា វិជ្ជាប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សាឆ្នាំទី១ របស់ក្រុមវិជ្ជាការក្រសួងសិក្សាធិការ (ភាសាថៃ) បឹងកក -ព. ស. ២៥១២ គ. ស. ១៩៦៨ ។

9. Dauphin Meunier, Histoire du Cambodge, PUF , Que sais -je ? Paris 1961.

10. -12- Henri Russier, Histoire sommaire du royaume du Cambodge des origines à nos jours (brochure ronéotypée), 1929 ?

11. Adhémard Leclère, le Sdach Kân, Imprimerie coloniale, Saigon, 1911.

13. Lê Thanh Khôi, Histoire de l'Asie du Sud - est, PUF , Que sais-je ? Paris, 1959.

14. B.P. Groslier, Angkor et le Cambodge au 16º siècle d'après les sources portugaises et espagnoles, Paris, 1958.

15. France- Asie, nº spécial 118-119, Présence du Royaume lao, Saigon. 1956.

16. ពង្សាវតារប្រទេសលាវ គឺក្រុងហ្លួងព្រះបាង ក្រុងវៀងចន្ទ ក្រុងជួន និងក្រុងចំប៉ាស័ក (ជាភាសាលាវ) - វៀងចន្ទ គ. ស. ១៩៦៧ ។ Annales de Laos-Luang Prabang- Vientiane - Tranninh et Bassac, publiées la 22e année du règne de S.M. Sisavang Vong Roi du Luang Prabang, 1926.

17. ឯកសារមហាបុរសខ្មែរ លេខ ២៧-២៨ របស់លោកអេងសុត បោះពុម្ពផ្សាយនៅក្រុងភ្នំពេញ នៅគ. ស. ១៩៦៩ ។

18. ប្រវត្តិវិទ្យា ភាគ ១ ថ្នាក់ទី ១ - ខេមរយានកម្ម - ភ្នំពេញ - ១៩៧២ ។

19. Lawrence Palmer Priggs, Les missionnaires portugais et espagnols au Cambodge (1555-1603), texte traduit de l'anglais par Monique Dupont et publié dans Fullectin de la Société des Etudes Indochinoises (Nouvelle série - Tome xxv, nº 1-1er trimestre 1950), Saigon, 1950.

20. H. Sutton, Singapore in history, federal publications, Singapore, 1967.

21. ព្រះរាជពិធីទ្វាទសមាស ភាគ ១ បោះពុម្ពលើកទី ២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០០ - គ.ស.១៩៥៦ ។

22. J. Imbert, Histoire des Institutions Khmères, volume II, Annales de la Faculté de Droit de Phnom Penh, 1961.

23. លោកអនុសេនីយឯក សឺននី - ប្រវត្តិយោធាខ្មែរ អត្ថបទផ្សាយតាមទូរទស្សន៍សាធារណរដ្ឋខ្មែរ ខែ មេសា ១៩៧៤ ។

24. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦ - ភ្នំពេញ ១៩៦៩ ។

25. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត-លេខ ១២-១៦-១៨ ភ្នំពេញ ១៩៦៩ ។

26. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

27. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ១៥ - ភ្នំពេញ គ.ស. ១៩៦៩ ។

28. សិលាចារឹកនគរវត្ត និងបទានុក្រម - ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស. ១៩៥៨ ។

29. គោលប្រវត្តិសាស្ត្រនៃអក្សរសាស្ត្រខ្មែរ ដោយប្រជុំសាស្ត្រាចារ្យ- ការផ្សាយរបស់បណ្ណាគារភ្នំពេញ - ភ្នំពេញ គ.ស. ១៩៥៦ ។

30. លោក ឃួន សុខម្ភូ - គំនិតរិះគន់សង្គមក្នុងអក្សរសិល្ប៍ខ្មែរ - សន្និសីទធ្វើនៅសាលាជាតិខាងរដ្ឋបាល នៅថ្ងៃទី ១ មិថុនា ១៩៧៤ នៅភ្នំពេញ ។

31. L'organisation buddhique au Cambodge, nº4 , Série Cuture et Civilisation Khmères, Phnom Penh, 1963.

32. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២២ - ភ្នំពេញ គ.ស. ១៩៦៩ ។

33. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ២៣ - ភ្នំពេញ គ.ស. ១៩៦៩ ។

34. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៧ - ភ្នំពេញ គ.ស. ១៩៦៩ ។

35. Madeleine Giteau, Depuis un siècle, un effort soutenu pour dégager et restaures Angkor, dans SOS Angkor, Courrier de L'Unesco, Décembre 1961.

36. ប្រជុំពង្សាវតារ ច្បាប់បណ្ណាល័យជាតិ-ក្បាលទី១ - រោងពុម្ពការហ្គា បោះពុម្ពលើកដំបូង - ក្បាលទី ១ ឧសភា ព.ស.២៥០៦ ( ជាភាសាថៃ) ។

37. Phan Khoang, Viêt Su : Xu Dang Trong 1558-1777, Saigon, 1969.

38. Lê Huong, Su Cac Miên, Saigon, 1970.

39. Charles Meyer, Phnom Penh, à la recherche du passé - les premiers occidenteaux à Phnom Penh, article publié dans Nokor Khmer, n°2, Phnom Penh, 1970.

40. Tran Trong Kim, Vietnam Su Luoc, Sagon, 1964.

41. G. Nandin, Histoire de la Cochinchine.

42. Jean Moura, Le Royaume du Cambodge, Paris, 1883.

43. ឯកសារមហាបុរសខ្មែរ របស់លោក អេងសុត - លេខ ៦៤ - ភ្នំពេញ គ.ស.១៩៦៩ ។

44. Adhémard Leclère, l'Histoire du Cambodge, Geuthner, Paris, 1914.

45. Lê Huong, Nguoi Viet gôc Miên, Sagon, 1969.

46. P. Schweisguth, un siècle d'histoire dans la péninsule indochinoise (1750-1850), Imprimerie Taupin et , Hanôi, 1944.

47. លោក កែវសុវត្ថិ - ចៅហ្វាយគុយ - ភ្នំពេញ - ១៩៧១ ។

48. Gérard Groussin,,Le protectorat Français sur le Cambodge de 1863 à 1884 (ronéotypé), Centre de documentation et de recherche de la Faculté des Lettres et des Sciences humaines de Phnom Penh, 1973.

49. Luang vichitr Vadakarn, Thailand's case, Bangkok, 1941.

50. Charles Meyer, Insurrections nationales du siècle dernier, dans Etudes cambodgiennes n° 9 , Phnom Penh, 1967.

51. M. Giteau, Histoire du Cambodge, Didier, Paris, 1957.

52. លោក ឱកគាម - អាចារ្យស្វា - ភ្នំពេញ គ.ស. ១៩៧៣ ។

53. La monarchie khmère, dans le Sangkum nº 5, décembre 1965, Phnom Penh.

54. L'histoire de Kralahom Kong par ImChhum (traduction libre Suon On et Charles Meyer), dans Etudes cambodgiennes nº 18, Phnom Penh, 1969.

55. Gaston Barrault, Cambodgiens de Cochinchine, Editions de la Revue Extrême - Orient, Saigon, 1927.

56. La frontière Khméro - vietnamienne, dans Etudes Cambodgiennes nº 7 Phnom Penh, 1966.

57. Sarin Chhak, Quelques faits historiques sur le tracé des frontières entre le Cambodge, le Laos et le Vietnam ចុះផ្សាយក្នុងទស្សនាវដ្ដីសាស្ត្រចារ្យ លេខ ១៤- ឆ្នាំទី ៥- ១៩៦៤ ។

58. La monarchie khmère, dans le Sangkum nº 6, Phnom Penh, 1966.

59. Ho Tong Peng, L'économie de l'hévéaculture en 1965, dans Etudes cambodgiennes nº 1, Phnom Penh, 1965.

60. លោក ឱកគាម និងលោក ឡើកអំ - ភូមិគីរិច្ឆាន - ភ្នំពេញ -គ.ស. ១៩៧១ ។

61. L'oeuvre de Sa Majesté Monivong, dans le Sangkum nº 8 Phnon Penh, 1966.